# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

**របាយការណ៍បញ្ចប់ការសិក្សា**

# ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ

## (របស់រដ្ឋបាលខេត្តកណ្តាល)

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះលោក **ថូ សូផាត**

សាស្ត្រាចារ្យណែនាំ
លោក **ថោង ចន្ត្រា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **២២**

ឆ្នាំចូលសិក្សា **២០១៨**
ឆ្នាំសរសេរសារណា **២០២២**

**ឆ្នាំសិក្សា ២០២១-២០២២**

# អារម្ភកថា

ដើម្បីវាស់ស្ទង់នូវសមត្ថភាព និងកម្រិតផ្នែកចំណេះដឹង ព្រមទាំងឆ្លើយតបទៅនឹងគោលបំណងរបស់ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលទាក់ទងនឹង"**ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ**( **របស់រដ្ឋបាលខេត្តកណ្ដាល** )"យកមកសិក្សា ស្រាវជ្រាវ និងបន្តចុះកម្មសិក្សាចាប់ពី**ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២** រហូតដល់**ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២** នៅ**រដ្ឋបាលខេត្តកណ្ដាល**។

មូលហេតុដែលខ្ញុំបាទសម្រេចចិត្តជ្រើសរើសយកប្រធានបទខាងលើនេះមកសិក្សា ស្រាវជ្រាវ ដោយហេតុយល់ឃើញថា នាពេលបច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា កំពុងយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពោលដូចជា **រដ្ឋបាលខេត្តកណ្ដាល** ដែលជាហេតុនាំឱ្យខ្ញុំបាទចង់ធ្វើការសិក្សា ស្វែងយល់ ឱ្យបានកាន់តែស៊ីជម្រៅ អំពីដំណើរការនីតិវិធីនៃការដោះស្រាយវិវាទនៅរដ្ឋបាលថ្នាក់ក្រោមជាតិនេះ។ យ៉ាងណាមិញ ទីចាត់ការអន្តរវិស័យ ជាទីចាត់ការមួយរបស់រដ្ឋបាលខេត្តកណ្ដាលដែលទទួលបន្ទុកសម្របសម្រួល ដោះស្រាយវិវាទចម្រុះជាច្រើន ពិសេសពាក់ព័ន្ធនឹងវិវាទដីធ្លី ដែលអាចឱ្យខ្ញុំបានស្វែងយល់បានច្រើនអំពីកិច្ចការងារដែលបានកើតមានឡើងនៅក្នុងមូលដ្ឋាន។ ទន្ទឹមនេះ ខ្ញុំក៏អាចចុះសិក្សា ស្រាវជ្រាវ ស្វែងរកឯកសារ និងនីតិវិធីបែបបទការបំពេញការងារផ្ទាល់ ដើម្បីតាក់តែង រៀបចំ សរសេររបាយការណ៍ នូវប្រធានបទដែលបានគ្រោងទុក។ ដូចច្នេះ ទើបខ្ញុំបានសម្រេចចិត្តលើកឡើងពីប្រធានបទខាងលើ មកស្រាវជ្រាវនៅក្នុងរដ្ឋបាលខេត្តកណ្ដាល និងចងក្រងជាឯកសារមួយទុកសម្រាប់ជាការថ្លឹងថ្លែងអំពីកម្រិតសមត្ថភាពនៃការយល់ដឹងផ្នែកជំនាញនីតិសាស្ត្រក្នុងអំឡុងពេលសិក្សាអស់រយៈពេល ០៤ឆ្នាំកន្លងផុតមកនេះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមធ្វើការអភ័យទោសទុកជាមុនរាល់កំហុសខុសឆ្គងទាំងឡាយណាដែលកើតមានឡើងដោយអចេតនា ដូចជាកំហុសឆ្គងផ្នែកអក្ខរាវិរុទ្ធ និងផ្នែកខ្លឹមសារនៅក្នុងរបាយការណ៍ទាំងមូលជាដើម។ ម្យ៉ាងវិញទៀត ទោះជាយ៉ាងណាក្ដីការសរសេររបស់ខ្ញុំបាទ ក៏គង់តែមានចំណុចខ្វះខាតជាក់ជាមិនខាន ដូច្នេះខ្ញុំបាទទន្ទឹងរង់ចាំស្វាគមន៍រាល់ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ គ្រូឧទ្ទេស សិស្សច្បង ព្រមទាំងនិស្សិតទាំងអស់ជាអ្នកអានពីគ្រប់មជ្ឈដ្ឋានដោយក្ដីគោរពស្រឡាញ់ និងរីករាយជាទីបំផុត។

**សូមគោរពអរគុណ និងថ្លែងអំណរគុណ**!!

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ថុ សុផាត** ជានិស្សិតជំនាន់ទី **២២** ផ្នែកនីតិសាស្រ្ត ឆ្នាំសិក្សា២០១៨ នៃ

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។**

**សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ!!**

1. លោកអ្នកមានគុណទាំងពីរគឺ**លោកឪពុក ភក ថុ** និង**អ្នកម្តាយ សោម ម៉ើ** ដែលជាព្រះកន្លោង លោកបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ ព្រមទាំងផ្គត់ផ្គង់ទាំងផ្នែកថវិកានឹងស្មារតីដល់រូបកូនក្នុងការសិក្សាតាំងពីតូចក្រូចឆ្មា រហូតដល់បច្ចុប្បន្នទទួលបានលទ្ធផលល្អដូចសព្វថ្ងៃនេះ ក៏ដូចជាសមាជិកទាំងអស់ក្នុងក្រុមគ្រួសារទាំងមូល។
2. លោក **ជាង រិទ្ធី** នាយកទីចាត់ការអន្តរវិស័យ លោក-លោកស្រីនាយករងទីចាត់ការ និងលោក **ទេព តារុណា** ប្រធានការិយាល័យកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ លោក-លោកស្រីអនុប្រធានការិយាល័យ និងមន្រ្តីរាជការស៊ីវិលក្នុងការិយាល័យចំណុះទាំងអស់ ដែលបានចូលរួមសហការផ្តល់ជូននូវឯកសារ និងព័ត៌មាន ព្រមទាំងណែនាំអំពីនីតិវិធី និងបែបបទការងារនៅទីចាត់ការអន្តរវិស័យដល់រូបខ្ញុំបាទ។
3. ថ្នាក់ដឹកនាំ សមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត នាយក-នាយករងរដ្ឋបាល នាយក-នាយករងទីចាត់ការ ប្រធាន-អនុប្រធានការិយាល័យ និងមន្រ្តីសាលាខេត្តទាំងអស់ ដែលបានសហការនឹងអនុញ្ញាតឱ្យរូបខ្ញុំបាទស្នើសុំឯកសារ និងសាកសួរនាំព័ត៌មានដែលពាក់ព័ន្ធជាមួយប្រធានបទខាងលើនៅអំឡុងពេលចុះកម្មសិក្សាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្រ្ត។
4. ថ្នាក់ដឹកនាំ ឯកឧត្តម សាស្រ្តាចារ្យ បណ្ឌិត លោក-លោកស្រីគ្រូឧទ្ទេស លោកគ្រូ-អ្នកគ្រូសម្របសម្រួលនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន និងជួយសម្របសម្រួលក្នុងដំណើរការសិក្សារៀនសូត្រកន្លងមកគ្រប់ពេលវេលាដល់រូបខ្ញុំបាទយ៉ាងយកចិត្តទុកដាក់ជាទីបំផុត ពិសេសតែងតែជួយបំពេញបន្ថែមនូវចំណុចខ្វះខាត។
5. លោកគ្រូ **ថោង ចន្រ្ទា** ដែលជាសាស្រ្តាចារ្យណែនាំដ៏មានគុណបំណាច់មួយរូប ក្នុងការជួយជ្រោមជ្រែងយកចិត្តទុកដាក់ពន្យល់ណែនាំ ផ្តល់នូវយោបល់ និងអនុសាសន៍ល្អៗ ដល់ការចុះស្រាវជ្រាវសរសេររបាយការណ៍របស់ខ្ញុំបាទ ពិសេសចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយកែលម្អស្នាដៃនេះជាបន្តបន្ទាប់ រហូតបញ្ចប់ទៅដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយ ល្អប្រសើរ និងទទួលបានជោគជ័យប្រកបដោយផ្លែផ្កា។

ជាទីបញ្ចប់ ខ្ញុំបាទសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី ព្រមទាំងវត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវតាឆ្នាំថ្មី សូមជួយថែរក្សាការពារ និងប្រោះព្រំប្រទានពរជ័យ បវរសួស្តីជ័យមង្គលវិបុលសុខគ្រប់ប្រការជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសម្រេចបាននូវជោគជ័យគ្រប់ភារកិច្ចការងារ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

## សេចក្តីផ្តើម

១.លំនាំបញ្ហា ............ ១

២.ចំណោទបញ្ហា ............ ១

៣.គោលបំណងនៃការចុះកម្មសិក្សា ............ ២

៤.កម្មវត្ថុនៃកម្មសិក្សា ............ ២

៥.រចនាសម្ព័ន្ធនៃការចងក្រងរបាយការណ៍ ............ ២

## ជំពូកទី១
## ទិដ្ឋភាពទូទៅរបស់រដ្ឋបាលខេត្តកណ្តាល

១.១.ស្ថានភាពទូទៅរបស់ខេត្តកណ្តាល ............ ៤

១.១.១.ប្រវត្តិខេត្ត ............ ៤

១.១.២.លក្ខណៈភូមិសាស្ត្រ ............ ៤

១.១.៣.រចនាសម្ព័ន្ធរដ្ឋបាលខេត្ត ............ ៥

១.១.៤.ផ្នែកសេដ្ឋកិច្ច ............ ៦

១.១.៥.ផ្នែកសង្គមកិច្ច ............ ៧

## ជំពូកទី២
## កិច្ចការងារប្រចាំថ្ងៃរបស់ទីចាត់ការអន្តរវិស័យ

២.១.លក្ខណៈទូទៅរបស់ទីចាត់ការអន្តរវិស័យ ............ ៨

២.១.១.តួនាទី មុខងារ និងភារកិច្ច ............ ៨

២.១.២.រចនាសម្ព័ន្ធទីចាត់ការអន្តរវិស័យ ............ ៨

២.២.របៀបរបបការងាររបស់ទីចាត់ការអន្តរវិស័យ ............ ៩

២.២.១.តួនាទីការិយាល័យចំណុះ ............ ៩

២.២.២.លទ្ធផលការអនុវត្តន៍ការងាររបស់ទីចាត់ការ ............ ១១

២.៣.លទ្ធផលកម្មសិក្សា ............ ១១

២.៣.១.ដំណើរការនៃការដោះស្រាយវិវាទ ............ ១១

២.៣.២.ការដោះស្រាយវិវាទតាមរយៈគណៈកម្មការរដ្ឋបាល ............ ១៣

២.៣.៣.ការសម្របសម្រួលតាមរយៈគណៈកម្មការសុរិយោដី ..... ១៤
ក.គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ..... ១៤
ខ.គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ..... ១៦
គ.គណៈកម្មការសុរិយោដីថ្នាក់ជាតិ ..... ១៨
២.៤.លក្ខណៈការងារបច្ចេកទេស ..... ២១
ក.ចរន្ត ឬវន្តនៃដំណើរនៃការដោះស្រាយវិវាទដីធ្លី ..... ២១
២.៥.ចំណុចខ្លាំង និងកាលានុវត្តភាព ..... ២២
ក.ចំណុចខ្លាំង ..... ២២
ខ.កាលានុវត្តភាព ..... ២២
២.៦.បញ្ហាប្រឈម និងសំណូមពរ ..... ២៣
ក.បញ្ហាប្រឈម ..... ២៣
ខ.សំណូមពរ ..... ២៣

**ជំពូកទី៣**

**សកម្មភាពការងារជាក់ស្តែង**

៣.១.ការអនុវត្តការងារ ..... ២៤
៣.២.ការចូលរួមកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ..... ២៤
៣.៣.ការចូលរួមដំណើរទស្សនកិច្ចសិក្សា ..... ២៥
**សេចក្តីសន្និដ្ឋាន** ..... ២៦
**អនុសាសន៍** ..... ២៨
**ឯកសារយោង** ..... ២៩
**តារាងឧបសម្ព័ន្ធ** ..... ៣០

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

នៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទូទៅបច្ចុប្បន្នរបស់ប្រទេសកម្ពុជា រដ្ឋបាលត្រូវបែងចែកជាពីរផ្នែកគឺរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ជាតិ គឺជាការប្រមូលផ្តុំនូវអាជ្ញាធររួមចូលគ្នាបានជាអំណាចនីតិប្រតិបត្តិ ដើម្បីជានាលើការគ្រប់គ្រង និងដឹកនាំប្រទេស។ រីឯ រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអង្គរដ្ឋបាលដែលទទួលបន្ទុកគ្រប់គ្រង និងចាត់ចែងកិច្ចការនានា នៅតាមដែនដីភូមិសាស្ត្រនីមួយៗរបស់ខ្លួន ពោលគឺសំដៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ជារដ្ឋបាលដែលនៅកៀកនឹងប្រជាពលរដ្ឋបំផុត។ សព្វថ្ងៃនេះរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការពង្រឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈនយោបាយប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ។ រដ្ឋបាលរាជធានី ខេត្ត គឺជារដ្ឋបាលដែនដីខ្ពស់ជាងគេបង្អស់ចំណុះឱ្យក្រសួងមហាផ្ទៃ និងជាតំណាងរាជរដ្ឋាភិបាល ដែលដឹកនាំដោយប្រធានក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត។ ជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងការដាក់ចេញនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋបាលរាជធានី ខេត្ត បានចូលរួម និងខិតខំប្រឹងបំពេញតួនាទី ភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម។ រដ្ឋបាលរាជធានី ខេត្ត មានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងលើគ្រប់វិស័យដើម្បី ថែរក្សាសណ្តាប់ធ្នាប់សាធារណៈប្រកបដោយសុខសន្តិភាព បរិយាកាសនយោបាយល្អ ការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋ និងលើកកម្ពស់កិត្យានុភាពអភិវឌ្ឍន៍ភូមិសាស្ត្ររាជធានី ខេត្ត ឆ្ពោះទៅរកវឌ្ឍនភាព និងវិបុលភាព ធ្វើឱ្យប្រជាពលរដ្ឋរស់នៅបានប្រកបដោយសុភមង្គល សុខដុមរមនា លើគ្រប់វិស័យដែលមានទីចាត់ការ មន្ទីរ អង្គភាពជំនាញចំណុះសហការចូលរួមជាច្រើន។

ដោយឡែក ទីចាត់ការអន្តរវិស័យ នៃសាលាខេត្តកណ្តាល ជាទីចាត់ការមួយដែលចំណុះឱ្យរដ្ឋបាលខេត្ត បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចនូវកិច្ចការមួយចំនួនក្នុងខេត្តពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច សាសនា សំណង់ ដីធ្លី បរិស្ថាន វប្បធម៌ អប់រំ សុខាភិបាល និងមានការិយាល័យចំណុះចំនួន ៣ ជាសានាធិការ។ ដូច្នេះហើយ ដើម្បីធ្វើការអភិវឌ្ឍន៍ចំណេះជំនាញរបស់ខ្ញុំបាទ លើការសិក្សាជំនាញនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំ និងស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីប្រព័ន្ធការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសរដ្ឋបាលខេត្តកណ្តាលផ្ទាល់ខ្ញុំបាទបានសម្រេចចិត្តកំណត់យកប្រធានបទមួយស្តីពី "**ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ(របស់រដ្ឋបាលខេត្តកណ្តាល)**" មកអនុវត្តន៍ និងសិក្សា អង្កេត ស្រាវជ្រាវជារបាយការណ៍បញ្ចប់ការសិក្សានេះ។

## ២.ចំណោទបញ្ហា

ដើម្បីលើកកម្ពស់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ រដ្ឋបាលខេត្តកណ្តាលបាននឹងកំពុងយកចិត្តទុកដាក់ពង្រឹងការអនុវត្តការងាររបស់ទីចាត់ការ មន្ទីរ អង្គភាព ជំនាញចំណុះខេត្តឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងការឆ្លើយតបជាមួយនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានទាន់ពេលវេលាដែលមានការចូលរួមយ៉ាងសកម្មរបស់ទីចាត់ការអន្តរវិស័យ ក្នុងការជួយសហការជាមួយស្ថាប័នអង្គភាពជំនាញតាមវិស័យទាក់ទង

កិច្ចការសំខាន់ៗនានា។ ដូច្នេះ ឆ្លងតាមការអង្កេត សិក្សា ស្វែងយល់ យ៉ាងយកចិត្តទុកដាក់ថា តើដំណើការនៃការអនុវត្តន៍ការងារ និងការដោះស្រាយវិវាទដីធ្លីរបស់ទីចាត់ការអន្តរវិស័យប្រព្រឹត្តទៅមានបែបបទលក្ខណៈ ឬនីតិវិធីយ៉ាងដូចម្ដេចខ្លះ? ហើយជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ?

## ៣.គោលបំណងនៃការចុះកម្មសិក្សា

ដើម្បីសម្រេចបានជាលទ្ធផល និងឆ្លើយតបទៅនឹងរាល់បញ្ហាដែលបានចោទឡើងខាងលើ ទើបខ្ញុំបាទធ្វើការចុះកម្មសិក្សា ដើម្បីអង្កេត ស្វែងយល់ អំពីនីតិវិធី និងដំណើរការនៃការអនុវត្តការងារ និងការដោះស្រាយវិវាទនានា នៅក្នុងការិយាល័យទាំងបីចំណុះនៃទីចាត់ការអន្តរវិស័យ ដើម្បីទទួលបាននូវព័ត៌មាន និងចំណេះដឹងជាក់ស្តែងសម្រាប់ខ្ញុំបាទផ្ទាល់ និងអ្នកសិក្សាក៏ដូចជាសិស្ស និស្សិតផ្សេងទៀត ដែលមានបំណងចង់ស្វែងយល់អំពីកិច្ចការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងអាចទទួលបាននូវបទពិសោធន៍នៃការប្រឈមនឹងការដោះស្រាយនូវបញ្ហានានាពាក់ព័ន្ធ ដែលកើតមានក្នុងមូលដ្ឋាន សហគមន៍ របស់ប្រជាពលរដ្ឋព្រោះរាល់ទុក្ខកង្វល់ទាំងនេះ ជាបញ្ហាចំបងមួយរបស់រាជរដ្ឋាភិបាលកម្ពុជា រួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនឈានទៅមុខតាមផែនការគ្រោងទុករបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ពិសេសជួយលើកកម្ពស់ផ្នែកជីវភាពរបស់ប្រជាពលរដ្ឋមួយកម្រិត និងធានានូវគុណភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រកបដោយសុភមង្គល សុខដុមរមនា ឆ្ពោះទៅរកវឌ្ឍនភាព និងវិបុលភាពដ៏រុងរឿងថ្កើនថ្កាន។

## ៤.កម្មវត្ថុនៃកម្មសិក្សា

ដោយសង្កេតឃើញថា រចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាលខេត្តកណ្តាល ត្រូវបានបែងចែកជាច្រើនទីចាត់ការ អង្គភាពចំណុះ និងការិយាល័យជំនាញ ដូចនេះទើបខ្ញុំបាទមិនអាចមានលទ្ធភាព និងពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការស្វែងយល់ឱ្យបានច្បាស់លាស់ អំពីប្រព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៅគ្រប់ទីចាត់ការ អង្គភាពចំណុះ និងការិយាល័យទាំងអស់បាននោះឡើយ អំពីចរន្តការរបស់លិខិតទាំងឡាយដែលប្រជាពលរដ្ឋដែលបានដាក់ពាក្យស្នើសុំមកកាន់រដ្ឋបាលខេត្តជួយសម្របសម្រួល និងដោះស្រាយ។ ទន្ទឹមនេះ យោងតាមស្ថានភាពជាក់ស្តែង ខ្ញុំបាទផ្តោតការសិក្សា ស្រាវជ្រាវ ចងក្រង ជារបាយការណ៍នេះ ដោយយកតែចំណុចសំខាន់ៗនៃប្រធានបទរបស់ខ្ញុំបាទគ្រោងទុក និងកិច្ចការងារបច្ចេកទេសមួយចំនួនមកបកស្រាយ រៀបរាប់ ចែករំលែក។

## ៥.រចនាសម្ព័ន្ធនៃការចងក្រងរបាយការណ៍

នៅក្នុងរបាយការណ៍នេះ ខ្ញុំបាទបានរៀបចំ តាក់តែង និងចងក្រងឡើងដោយបែងចែកជា ០៣ ជំពូកធំៗដាច់ពីគ្នាដោយមិនរាប់បញ្ចូលនូវសេចក្តីផ្តើម និងសេចក្តីសន្និដ្ឋានឡើយ ដើម្បីងាយស្រួលក្នុងការសិក្សា ស្វែងយល់ និងធ្វើការវាយតម្លៃផ្តល់មតិលើសមត្ថភាពរបស់ខ្ញុំបាទបន្ថែមទៀតមានដូចខាងក្រោម៖

១.ជំពូកទី១៖ **"ទិដ្ឋភាពទូទៅរបស់រដ្ឋបាលខេត្តកណ្តាល"** គឺជាការរៀបរាប់អំពីប្រវត្តិលក្ខណៈភូមិ-សាស្ត្រសង្ខេបរបស់ខេត្ត ព្រមទាំងតួនាទី ភារកិច្ច រចនាសម្ព័ន្ធរដ្ឋបាលខេត្ត រួមជាមួយស្ថានភាពសេដ្ឋកិច្ច និងស្ថានភាពសង្គមកិច្ចរបស់ភូមិសាស្ត្រខេត្តកណ្តាលទាំងមូលតែម្តង។

២.ជំពូកទី២៖ **"កិច្ចការងារប្រចាំថ្ងៃរបស់ទីចាត់ការអន្តរវិស័យ"** គឺជាការរៀបរាប់ពីលក្ខណៈទូទៅរបស់ទីចាត់ការ រចនាសម្ព័ន្ធទីចាត់ការ មុខងារភារកិច្ច និងនីតិវិធីបែបបទការងាររបស់ការិ-យាល័យជំនាញទាំង ៣ ចំណុះទីចាត់ការ ពិសេសឆ្លើយតប អំពីលទ្ធផលនៃកម្មសិក្សាដែលខ្ញុំបាទបានចុះមកសិក្សា ស្រាវជ្រាវ ក្នុងទីចាត់ការអស់រយៈពេលកន្លងមក ព្រមទាំងចំណុចខ្លាំង បញ្ហាប្រឈម និងកាលានុវត្តភាព នៃដំណើរការអនុវត្តការងារប្រចាំថ្ងៃរបស់មន្ត្រីក្នុងទីចាត់ការ។

៣.ជំពូកទី៣៖ **"សកម្មភាពការងារជាក់ស្តែង"** គឺជាការនិយាយ រៀបរាប់ អំពីការអនុវត្តន៍ការងារ ការចូលរួមកិច្ចការប្រជុំ ដំណើរទស្សនកិច្ច និងកម្មវិធីផ្សេងៗ ដែលខ្ញុំបាទបានបំពេញភារកិច្ចក្នុងអំឡុងពេលចុះកម្មសិក្សានៅរដ្ឋបាលខេត្តកណ្តាល។

# ជំពូកទី១៖ ទិដ្ឋភាពទូទៅរបស់រដ្ឋបាលខេត្តកណ្តាល

## ១.១.ស្ថានភាពទូទៅរបស់ខេត្តកណ្តាល

### ១.១.១.ប្រវត្តិខេត្ត[1]

ខេត្តកណ្តាល ជាខេត្តមួយស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជាមានទីរួមខេត្តនៅក្នុងភូមិសាស្ត្រក្រុងតាខ្មៅ។ ខេត្តនេះជាឈ្មោះខេត្តមួយក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនៃប្រទេសកម្ពុជា ពាក្យនេះពុំដឹងជាមានប្រវត្តិ និងប្រភពដើមតាំងពីពេលណានោះទ្បើយ ប៉ុន្តែតាមការសិក្សា ស្រាវជ្រាវ បានឱ្យដឹងថាក្នុងផែនទីព្រះបាទនរោត្តម(១៨៦០-១៩០៤)នឹងផែនទីព្រះបាទស៊ីសុវត្ថិ(១៩០៤-១៩២៧)ព្រះរាជាណាចក្រកម្ពុជាចែកចេញជាច្រើនខេត្ត ក្នុងនោះពុំមានឈ្មោះខេត្តកណ្តាលទេ កាលនោះឈ្មោះខេត្តមួយចំនួនជាឈ្មោះស្រុកសព្វថ្ងៃដូចជា ខេត្តល្វាឯម ខេត្តស្អាង ខេត្តកោះធំ ខេត្តកណ្តាលស្ទឹងជាដើម(ឯកសារមហាបុរស)។ បើតាមកំណត់ត្រាចារឹកនៅចេតិយព្រះបាទអង្គឌួង និងចេតិយបុរាណជាច្រើនទៀត លើភ្នំព្រះរាជទ្រព្យ(ស្រុកពញាឮ)បានឱ្យឃើញថា ក្នុងរាជព្រះបាទនរោត្តមស៊ីសុវត្ថិ ភ្នំព្រះរាជទ្រព្យនេះស្ថិតនៅក្នុងភូមិសាស្ត្រខេត្តសំរោងទង(ឈ្មោះស្រុកមួយរបស់ខេត្តកំពង់ស្ពឺសព្វថ្ងៃនេះ) ប៉ុន្តែក្រោយមក ក្នុងរាជ្យព្រះបាទស៊ីសុវត្ថិមុនីវង្ស(១៩២៧-១៩៤១)មានការរៀបចំព្រំប្រទល់ខេត្តថ្មី ដូច្នេះ ទើបភ្នំព្រះរាជទ្រព្យត្រូវស្ថិតនៅក្នុងខេត្តកណ្តាលវិញ(កំណត់ត្រាចារឹកចេតិយព្រះស៊ីសុវត្ថិ)។ ផ្អែកតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថា ខេត្តកណ្តាលត្រូវបានកើតមានក្នុងរចនាសម្ព័ន្ធរដ្ឋបាលប្រទេសកម្ពុជាចាប់តាំងពីរាជ្យព្រះស៊ីសុវត្ថិ-មុនីវង្ស សម័យអាណានិគមបារាំងគ្រប់គ្រងមកទល់សម័យបច្ចុប្បន្ននេះ។

### ១.១.២.លក្ខណៈភូមិសាស្ត្រ[2]

ខេត្តកណ្តាល គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ដែលលាតសន្ធឹងនឹងហ៊ុំព័ទ្ធរាជធានីភ្នំពេញ តាមបណ្តោយដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់មានចម្ងាយប្រមាណ ១១គីឡូម៉ែត្រ ពីវត្តភ្នំ និងមានព្រំប្រទល់ខាងលិចទល់នឹងខេត្តកំពង់ស្ពឺ ខាងកើតទល់នឹងខេត្តព្រៃវែង ខាងជើងទល់នឹងខេត្តកំពង់ឆ្នាំង និងកំពង់ចាម ខាងត្បូងទល់នឹងខេត្តតាកែវ និងខេត្តអានយ៉ាងនៃប្រទេសវៀតណាម។ ខេត្តកណ្តាលមានផ្ទៃដីសរុប ៣,២១១.៧៥៩ គីឡូម៉ែត្រការ៉េ មានក្រុងចំនួន០១ ស្រុកចំនួន១០ ឃុំ-សង្កាត់ចំនួន១២៧ និងភូមិចំនួន ១,០១០ភូមិ។ នៅក្នុងឆ្នាំ២០១៨ ប្រជាពលរដ្ឋក្នុងខេត្តមានចំនួន ១,២២៧.៨៩០នាក់ ស្រីចំនួន ៦២៥,៥៨៦នាក់ ប្រជាពលរដ្ឋមានអាយុ ១៨ឆ្នាំឡើងចំនួន ៧៨៤,០០៨នាក់ គ្រួសារមានចំនួន ២៦៤,៥០៦គ្រួសារ មានដង់ស៊ីតេប្រជាជនចំនួន ៣៨៣នាក់/គីឡូម៉ែត្រការ៉េ។ ខេត្តកណ្តាល មានសក្តានុពលលើវិស័យកសិកម្មផ្នែកការងារបង្កបង្កើនផលស្រូវ នេសាទ និងដំណាំចម្រុះ ព្រមទាំងជាមូលដ្ឋានវិស័យពាណិជ្ជកម្ម អាជីវកម្ម ឧស្សាហកម្មថែមទៀតផង។

[1] គេហទំព័រhttps://km.wikipedia.org/wiki/ខេត្តកណ្តាល

[2] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២១ ខេត្តកណ្តាល ចេញផ្សាយខែមករា ឆ្នាំ២០១៩

ខេត្តកណ្ដាលមានច្រកទ្វារព្រំដែនចំនួន ០៤ រួមមានដូចជា ច្រកទ្វារអន្តរជាតិក្អមសំណរ ច្រកទ្វារអន្តរជាតិជ្រៃធំ ច្រកទ្វារព្រំដែនព្រែកជ្រៃ-ព្រែកទន្លា និងច្រកទ្វារព្រំដែនព្រែកស្បូវ ដែលបម្រើឱ្យការងារពាណិជ្ជកម្មអន្តរជាតិ។

### ១.១.៣.រចនាសម្ព័ន្ធរដ្ឋបាលខេត្ត[3]

បន្ទាប់ពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានដាក់ឱ្យប្រើប្រាស់អំពីរចនាសម្ព័ន្ធ និងសមាសភាពថ្នាក់ដឹកនាំក្រុមប្រឹក្សាខេត្ត អាណត្តិទី៣ ត្រូវបានទទួលស្គាល់ដោយប្រកាសលេខ ០៧៤១ ប្រ.ក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ និងរចនាសម្ព័ន្ធរដ្ឋបាលខេត្តកណ្ដាល ត្រូវបានរៀបចំយោងតាមប្រកាសលេខ ៤២៧៤ ប្រ.ក ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការ នៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទីភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ប្រកាសលេខ ៣២៤ សហវ/ប្រ.ក ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសេចក្តីសម្រេចស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ ក្រុង ស្រុក ខណ្ឌ មានដូចខាងក្រោម៖

- **ក្រុមប្រឹក្សាខេត្ត**: ក្នុងអាណត្តិទី៣នេះ ក្រុមប្រឹក្សាខេត្តដឹកនាំដោយប្រធានក្រុមប្រឹក្សា ០១រូប គឺ**ឯកឧត្តមបណ្ឌិត ម៉ៅ ធនិរុណា** មានសមាជិក និងសមាជិកាចំនួន ២៦រូប ព្រមទាំងគណៈកម្មាធិការកាតព្វកិច្ចចំណុះចំនួន០៣ គឺគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ គណៈកម្មាធិការបច្ចេកទេស និងគណៈកម្មាធិការលទ្ធកម្ម។
- **គណៈអភិបាលខេត្ត**: គ្រប់គ្រងដឹកនាំដោយអភិបាលខេត្ត ០១រូប គឺ**ឯកឧត្តម គង់ សោភ័ណ្ឌ** ទទួលបន្ទុកដឹកនាំការងាររួម និងការងាររដ្ឋបាលទូទៅ ព្រមទាំងមានគណៈអភិបាលរងចំនួន ០៦រូប ជាអ្នកជួយសម្រួលកិច្ចការនានាជូនអភិបាលខេត្ត។
- **នាយករដ្ឋបាលសាលាខេត្ត**: ដឹកនាំដោយនាយករដ្ឋបាល ០១រូប គឺ**លោក គ្រុយ ម៉ាឡែន** មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាល និងអភិបាលខេត្ត ក្នុងការចាត់ចែងកិច្ចការរដ្ឋបាលប្រចាំថ្ងៃ ព្រមទាំងមាននាយករងរដ្ឋបាលចំនួន ០៤រូប ជាសេនាធិការ។
- **ទីចាត់ការរដ្ឋបាល**: ដឹកនាំដោយនាយកទីចាត់ការ ០១រូប គឺ**លោក ម៉ូ សារឿន** និងនាយករងទីចាត់ការចំនួន ០២រូប ជាជំនួយការ ព្រមទាំងមានការិយាល័យចំណុះចំនួន ០៥ ការិយាល័យ។

[3] គេហទំព័រដើមរបស់រដ្ឋបាលខេត្តកណ្ដាល(https://www.kandal.gov.kh)

- **ទីចាត់ការផែនការ និងវិនិយោគៈ** ដឹកនាំដោយនាយកទីចាត់ការ ០១រូប គឺ**លោក នឹម នីរ៉ាដេត** និងនាយករងទីចាត់ការចំនួន ០២រូប ជាជំនួយការ ព្រមទាំងមានការិយាល័យចំណុះចំនួន ០៤ ការិយាល័យ។
- **ទីចាត់ការគ្រប់គ្រងធនធានមនុស្សៈ** ដឹកនាំដោយនាយកទីចាត់ការ ០១រូប គឺ**លោក គន្ធ ច័ន្ទណែត** និងនាយករងទីចាត់ការចំនួន ០២រូប ជាជំនួយការ ព្រមទាំងមានការិយាល័យចំណុះចំនួន ០២ ការិយាល័យ។
- **ទីចាត់ការអន្តរវិស័យៈ** ដឹកនាំដោយនាយកទីចាត់ការ ០១រូប គឺ**លោក ខាង រិទ្ធី** និងនាយករងទីចាត់ការចំនួន ០២រូប ជាជំនួយការ ព្រមទាំងមានការិយាល័យចំណុះចំនួន ០៣ ការិយាល័យ។
- **អង្គភាពច្រកចេញចូលតែមួយៈ** ដឹកនាំដោយប្រធានអង្គភាព ០១រូប គឺ**លោក រស់ សុធា** និងអនុប្រធានចំនួន ០២រូប។
- **អង្គភាពលទ្ធកម្មៈ** ដឹកនាំដោយលោកប្រធាន **ខុន លីម៉ូរ៉ា** និងអនុប្រធានចំនួន ០២រូប ជាជំនួយការ។

### ១.១.៤.ផ្នែកសេដ្ឋកិច្ច[4]

ស្ថានភាពសេដ្ឋកិច្ចក្នុងភូមិសាស្ត្រខេត្តកណ្ដាល បងប្អូនប្រជាពលរដ្ឋប្រកបរបរកសិកម្មជាចំបង ពោលគឺមានចំនួន ៣១៣,៩៧៨នាក់ ស្មើនឹង ៥៥,៧% ធ្វើការដាំដុះដំណាំជាច្រើនប្រភេទដូចជា ស្រូវ បន្លែបង្ការ ស្វាយ ល្ហុង ពោត ឈូក សណ្ដែក ដំណាំរយៈពេលខ្លី ដំណាំរយៈពេលវែង ហើយក៏មានគ្រួសារចិញ្ចឹមសត្វ និងនេសាទត្រីដើម្បីបង្កើនប្រាក់ចំណូលសម្រាប់ដោះស្រាយជីវភាពប្រចាំថ្ងៃថែមទៀតផង។ ចំពោះអ្នកមានមុខរបរចម្បងក្រៅពីវិស័យកសិកម្មមានចំនួន ២៤៤,៧១៥នាក់ ស្មើនឹង ៤៤,៣% ក្នុងនោះ អ្នកប្រកបរបរផ្នែកផលិតកម្មមានចំនួនប្រមាណ ៥,៨១៨នាក់ និងប្រជាពលរដ្ឋប្រកបរបរផ្នែកសេវាកម្មមានចំនួនប្រមាណ ២៣៨,៨៩៧នាក់។ ក្នុងឆ្នាំ២០១៨ ទីតាំងផលិតកម្ម និងសេវាកម្មក្នុងខេត្តកណ្ដាលមានចំនួន ១៣,៩៥១កន្លែង ដែលមានប្រជាពលរដ្ឋបម្រើការងារក្នុងវិស័យនោះចំនួនប្រមាណ ៣៣,៦៣៨នាក់។ ចំណែកឯ វិស័យឧស្សាហកម្មសិប្បកម្ម និងតំបន់ឧស្សាហកម្មវាយនភ័ណ្ឌ ភាគច្រើនប្រមូលផ្ដុំនៅបណ្ដាស្រុកមួយចំនួនដូចជា ស្រុកអង្គស្នួល ស្រុកកៀនស្វាយ និងស្រុកខ្សាច់កណ្ដាល។ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកណ្ដាល មានរោងចក្រសហគ្រាសសរុបចំនួនប្រមាណ ១៣៩កន្លែង និងផ្នែកផ្សេងៗចំនួនប្រមាណ ៥២កន្លែង ដែលបានស្រូបទាញយកកម្លាំងកម្មករ កម្មការិនី ឱ្យមានឱកាសទទួលបានការងារធ្វើ ជាពិសេស ជួយសម្រួលដល់ជីវភាពបងប្អូនប្រជាពលរដ្ឋចំនួនប្រមាណជា ១៥ម៉ឺននាក់ ទូទាំងខេត្ត។ ចំណែកឯ វិស័យពាណិជ្ជកម្មមានភាពអំណោយផលដោយខេត្តកណ្ដាល ជាខេត្តដែលហ៊ុំព័ទ្ធរាជធានីភ្នំពេញ និងមានច្រកព្រំដែនជាតិ និងអន្តរ-ជាតិ អស់រយៈពេលកន្លងមកខេត្តទទួលបានជោគជ័យយ៉ាងច្រើន ក្នុងការធ្វើពិពណ៌បង្ហាញផលិតផលនៅថ្នាក់ខេត្ត

[4] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២១ ខេត្តកណ្ដាល ចេញផ្សាយខែមករា ឆ្នាំ២០១៩

ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិចំនួន ២៤លើក មកហើយ។ ក្នុងន័យនេះ ស្ថិតនៅលើគ្រប់វិស័យដែលកំពុងតែមានទីតាំងនៅក្នុងខេត្តកណ្ដាល បានជួយលើកកម្ពស់ និងកាត់បន្ថយភាពក្រីក្ររបស់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋានជាច្រើន។

**១.១.៥.ផ្នែកសង្គមកិច្ច**[5]

ចំពោះស្ថានភាពសង្គមកិច្ចក្នុងខេត្តកណ្ដាល រដ្ឋបាលខេត្តបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាក្នុងការគាំទ្រផ្នែកសង្គមកិច្ចក្នុងខេត្តដូចជា វិស័យអប់រំ វិស័យសុខាភិបាល សាសនា និងវិស័យផ្សេងៗជាច្រើនទៀត ក្នុងវិស័យអប់រំសាលារៀន គឺជាចំណុចចាប់ផ្ដើមដំបូងនៃសក្ដានុពលគ្រប់គ្រង និងគុណភាពអប់រំក្នុងខេត្តដោយសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានគិតគូរនឹងផ្ដួចផ្ដើមឱ្យមានសាលាចាប់ពីកម្រិតថ្នាក់មត្តេយ្យសិក្សា ដល់កម្រិតវិទ្យាល័យចំនួន ៧៤៣សាលា ក្នុងនោះមានគ្រូបង្រៀនសរុបចំនួនប្រមាណ ៨,៩៣១នាក់ និងចំនួនសិស្សានុសិស្សចំនួនប្រមាណ ២៤៦,៥១៤នាក់។ ចំណែកឯ ការងារសុខាភិបាលខេត្តកណ្ដាលបាននឹងកំពុងបម្រើសេវាសុខភាពជូនប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរ ជាក់ស្ដែងវិស័យនេះមានមន្ទីរពេទ្យបង្អែកសំខាន់ៗចំនួន ១០កន្លែង មណ្ឌលសុខភាពចំនួន ៩៨កន្លែង និងប៉ុស្ដិ៍សុខភាពចំនួន ០២កន្លែង សម្រាប់បម្រើសេវាកម្មសុខាភិបាល ជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានគ្រប់បណ្ដាក្រុង ស្រុក ទូទាំងភូមិសាស្ត្រខេត្តកណ្ដាល។

ចំពោះវិស័យសាសនាប្រជាពលរដ្ឋក្នុងខេត្តកណ្ដាលគោរពព្រះពុទ្ធសាសនាប្រមាណ៩៨% នៃចំនួនប្រជាពលរដ្ឋសរុបដែលមានវត្តអារាមចំនួន ៣៥០វត្ត សម្រាប់ឱ្យប្រជាពលរដ្ឋ បន់ស្រន់ គោរពបូជា ប្រតិបត្តិតាមទំនៀមទំលាប់ប្រពៃណី និងប្រជាជនប្រមាណចំនួន ០៣% គោរពសាសនាផ្សេងទៀត រួមទាំងគ្រីស្តសាសនាមានព្រះវិហារចំនួន ១០៣ព្រះវិហារ សាសនាមហាយានមានព្រះវិហារចំនួន ១៨ និងសាសនាឥស្លាមមានព្រះវិហារចំនួន ១៩វិហារ។

[5] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២១ ខេត្តកណ្ដាល ចេញផ្សាយខែមករា ឆ្នាំ២០១៩

# ជំពូកទី២៖ កិច្ចការងារប្រចាំថ្ងៃរបស់ទីចាត់ការអន្តរវិស័យ

## ២.១.លក្ខណៈទូទៅរបស់ទីចាត់ការអន្តរវិស័យ

### ២.១.១.តួនាទី មុខងារ និងភារកិច្ច[6]

ទីចាត់ការអន្តរវិស័យ គឺជាសេនាធិការមួយរបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ក្នុងការសហការជាមួយស្ថាប័នអង្គភាពជំនាញពាក់ព័ន្ធ និងមានគណនេយ្យភាពចំពោះគណៈអភិបាលខេត្ត ហើយមានតួនាទីភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- កិច្ចសម្របសម្រួលក្នុងការពិនិត្យមើលឡើងវិញនូវមុខងារ ធនធាន និងការទទួលខុសត្រូវ ដើម្បីផ្ទេរមកឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅក្នុងខេត្ត ក្រុង
- កិច្ចសហការសម្របសម្រួលក្នុងការប្រគល់ និងធ្វើប្រតិភូកម្មមុខងារ និងធនធានដល់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់នៅក្នុងខេត្ត
- កិច្ចសហការសម្របសម្រួលអនុវត្តមុខងារ ភារកិច្ចនានា ដែលទាក់ទងការងារសេដ្ឋកិច្ច ការលើកកម្ពស់សុខុមាលភាពសង្គម ការងារពាក់ព័ន្ធដីធ្លី ផែនការ រៀបចំដែនដីខេត្ត ឧទ្យាន ការងារបរិស្ថានធនធានធម្មជាតិ ការគ្រប់គ្រងសំណល់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូនព្រមទាំងការផ្តល់សេវាសាធារណៈនានា លើកលែងតែមុខងារភារកិច្ចទាំងឡាយណា ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ទីចាត់ការនានានៃរដ្ឋបាលខេត្ត
- ការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតាមដានត្រួតពិនិត្យ វាយតម្លៃការយល់ដឹងអំពីច្បាប់ និងការអនុវត្តច្បាប់
- ការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស ការគោរពសិទ្ធិមនុស្ស និងយេនឌ័រ
- ការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់ខេត្ត និងការដោះស្រាយវិវាទនៅមូលដ្ឋាន
- ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការលើកកម្ពស់សុវត្ថិភាពសង្គម
- ការអនុវត្តមុខងារ ភារកិច្ចថ្មី ដែលបានផ្ទេរមកឱ្យរដ្ឋបាលខេត្ត លើកលែងតែមុខងារ ភារកិច្ចដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ទីចាត់ការនានានៃរដ្ឋបាលខេត្ត។

### ២.១.២.រចនាសម្ព័ន្ធទីចាត់ការអន្តរវិស័យ

ក្នុងទីចាត់ការអន្តរវិស័យ នៃរដ្ឋបាលខេត្តកណ្តាល មានមន្ត្រីសរុបមានចំនួន ៣៥នាក់ ក្នុងនោះមន្ត្រីជាប់កិច្ចសន្យា ០១នាក់ និងកម្មសិក្សាការីស្ម័គ្រចិត្តចំនួន ២១នាក់។ ស្របតាមស្មារតីប្រកាសលេខ ៤២៧៤ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យ

---

[6] មាត្រា៥៨ អនុក្រឹត្យ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង/ស្រុក របស់រាជរដ្ឋាភិបាល

នៃសាលាស្រុក និងការកំណត់តួនាទីភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ របស់ក្រសួងមហាផ្ទៃ ទីចាត់ការអន្តរវិស័យនៃសាលាខេត្តកណ្តាល ត្រូវបានបែងចែករចនាសម្ព័ន្ធដូចខាងក្រោម៖

- នាយកទីចាត់ការចំនួន ០១រូប
- នាយករងទីចាត់ការចំនួន ០២រូប
- ការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់ មានប្រធាន ០រូប អនុប្រធាន ០២រូប និងមន្ត្រី ១០រូប
- ការិយាល័យកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ មានប្រធាន ០១រូប អនុប្រធាន ០២រូប និងមន្ត្រី ០៨រូប
- ការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច មានប្រធាន ០១រូប អនុប្រធាន ០២រូប និងមន្ត្រី ០៥រូប។

## ២.២.របៀបរបបការងាររបស់ទីចាត់ការអន្តរវិស័យ

### ២.២.១.តួនាទីការិយាល័យចំណុះ[7]

ទីចាត់ការអន្តរវិស័យ មានការិយាល័យចំណុះចំនួន ០៣ ការិយាល័យ ជាសេនាធិការមានតួនាទី ភារកិច្ចដូចខាងក្រោម៖

➢ **ការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច**

- គ្រប់គ្រងស្ថិតិអំពីមូលដ្ឋានអាជីវកម្ម និងផលិតកម្មគ្រប់ប្រភេទក្នុងខេត្ត
- សហការអនុវត្តការងារ តាមដាន វាយតម្លៃអំពីការធ្វើអាជីវកម្ម ផលិតកម្មគ្រប់ប្រភេទនៅក្នុងខេត្ត ជាមួយមន្ទីរជំនាញ និងអង្គភាពនានា តាមការធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័ន
- សិក្សាលើកយោបល់អំពីការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងការប្រកបមុខរបរក្នុងខេត្ត
- កំណត់គោលការណ៍អំពីការគ្រប់គ្រងទីផ្សារ និងសត្តឃាតដ្ឋាន
- សហការ សម្របសម្រួល ក្នុងការពិនិត្យមើលឡើងវិញនូវមុខងារ ការទទួលខុសត្រូវ និងធនធាន ដើម្បីផ្ទេរមករដ្ឋបាលខេត្ត
- សហការ សម្របសម្រួល ដើម្បីលើកកម្ពស់ការផ្តល់សេវាអប់រំ សុខាភិបាល និងអនាម័យក្នុងខេត្ត
- សហការ អប់រំ ផ្សព្វផ្សាយ អំពីកម្មវិធីបង្កាជំងឺសេវាសាធារណៈ
- សហការ សម្របសម្រួល ដើម្បីដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធដល់ការជួយសង្គ្រោះជនទីទ័លក្រ និវត្តន៍ជន ជនពិការ កុមារកំព្រា ជនអនាថា ជនគ្មានទីពឹង
- សហការ សម្របសម្រួល ក្នុងការពិនិត្យមុខងារ ការទទួលខុសត្រូវ និងធនធាន ដើម្បីផ្ទេរទៅឱ្យខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

[7] ប្រការ៧ ប្រកាសលេខ ៤២៧៤ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទីភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះរបស់ក្រសួងមហាផ្ទៃ

- ចាត់វិធានការការពារទ្រព្យសម្បត្តិសាធារណៈ ថែរក្សាសម្បត្តិវប្បធម៌ និងបេតិកភ័ណ្ឌជាតិ ធនធានធម្មជាតិ និងបរិស្ថាន
- ដោះស្រាយបញ្ហាពលកម្ម ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- វិធានការបង្ការគ្រោះធម្មជាតិ គ្រោះថ្នាក់សង្គម និងការជួយសង្គ្រោះ
- លើកកម្ពស់សុខុមាលភាពដល់ស្ត្រី កុមារ
- បញ្ជ្រាបយេនឌ័រគ្រប់សកម្មភាពសង្គម
- សម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងជំនឿ សាសនា វប្បធម៌ ប្រពៃណីក្នុងខេត្ត
- សម្របសម្រួលអន្តរវិស័យ ដើម្បីជម្រុញលើកកម្ពស់ការបង្កើតបរិស្ថានធុរកិច្ចល្អប្រសើរសម្រាប់ធ្វើសកម្មភាពសេដ្ឋកិច្ចគ្រប់ប្រភេទ សំដៅជំរុញឱ្យមានការវិនិយោគ និងការអភិវឌ្ឍឯកជននៅខេត្ត។

➢ **ការិយាល័យកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ**

- កំណត់គោលការណ៍ និងវិធានការអំពីការប្រើប្រាស់យានយន្ត និងមធ្យោបាយធ្វើដំណើរផ្សេងទៀតក្នុងខេត្ត និងសម្របសម្រួលតម្រង់ទិសការអនុវត្ត
- កំណត់គោលការណ៍ វិធានអំពីសុវត្ថិភាពចរាចរណ៍ក្នុងខេត្ត និងសម្របសម្រួលការអនុវត្ត
- គ្រប់គ្រងប្រព័ន្ធចរាចរណ៍ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទក្នុងខេត្ត
- គ្រប់គ្រងដំណើរការមជ្ឈមណ្ឌលព្យាបាលគ្រឿងញៀនផ្សេងៗទៀត
- អំពីការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់ខេត្ត
- កំណត់គោលការណ៍ និងវិធានការទប់ស្កាត់ និងប្រឆាំងឧក្រិដ្ឋកម្ម និងបទល្មើសនានា ព្រមទាំងរក្សាសុវត្ថិភាពក្នុងខេត្ត
- សហការ ស្រាវជ្រាវ អំពីអ្នកញៀនគ្រឿងញៀន និងរៀបចំគោលនយោបាយនានា ស្តីពីការបង្កាទប់ស្កាត់ និងប្រឆាំងគ្រឿងញៀន
- ទទួលពិនិត្យ និងលើកយោបល់ អំពីការដោះស្រាយវិវាទនានានៅមូលដ្ឋាន
- ទទួលពិនិត្យ និងលើកយោបល់ ចំពោះពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋចំពោះរដ្ឋបាលនានាក្នុងដែនសមត្ថកិច្ចរបស់ខេត្ត
- អប់រំ ផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស និងការគោរពសិទ្ធិមនុស្ស
- ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតាមដាន ត្រួតពិនិត្យ វាយតម្លៃការយល់ដឹងអំពីច្បាប់ និងការអនុវត្តច្បាប់
- ចូលរួមក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត និងសហការតាមដានអនុវត្តការសម្រេចនៃកិច្ចប្រជុំនេះ។

➤ **ការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់**

- សហការរៀបចំផែនការ ការរៀបចំដែនដីខេត្ត
- ពិនិត្យ និងផ្តល់យោបល់លើគម្រោងអភិវឌ្ឍនានា ដើម្បីឱ្យស្របតាមផែនការរៀបចំដែនដីខេត្ត
- ការងារពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លី
- តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍អំពីការអនុវត្តផែនការរៀបចំដែនដីខេត្ត និងប្លង់សំណង់
- កំណត់គោលការណ៍គ្រប់គ្រងសំណង់ចាស់ និងបេតិកភ័ណ្ឌក្នុងខេត្ត
- សហការកំណត់អំពីគោលការណ៍ក្នុងការអភិវឌ្ឍ និងថែទាំផ្លូវសធុលហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងខេត្ត
- ពិនិត្យ និងផ្តល់យោបល់លើបទល្មើសនៃការសាងសង់សំណង់នានា
- ការតាំងទីលំនៅថ្មី ការរក្សាសណ្តាប់ធ្នាប់ នគរូបនីយកម្ម និងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ។

### ២.២.២.លទ្ធផលការអនុវត្តន៍ការងាររបស់ទីចាត់ការ[8]

ក្នុងឆ្នាំ២០២១ ទីចាត់ការអន្តរវិស័យ បានទទួលរៀបចំតាក់តែងលិខិត និងចរាចរណ៍លិខិតរដ្ឋបាលសរុបចំនួន ៥,៣២៨ច្បាប់ ក្នុងនោះលិខិតរដ្ឋបាលចូលទៅការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច មានចំនួន ១២៩ច្បាប់ ការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់ចំនួន ១៤៦ច្បាប់ និងការិយាល័យកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈចំនួន ៥,០៨៣ច្បាប់ ហើយបានធ្វើចំណាត់ការលើលិខិតចំនួន ៧៣៣ច្បាប់។ ទន្ទឹមនេះ ទីចាត់ការអន្តរវិស័យដែលទទួលបន្ទុកលើការដោះស្រាយពាក្យបណ្តឹង និងការសម្របសម្រួលទំនាស់ជូនប្រជាពលរដ្ឋ ដែលពាក្យស្នើសុំមកកាន់រដ្ឋបាលខេត្តសម្របសម្រួល និងដោះស្រាយ សរុបចំនួន ២៦១ករណី ក្នុងនោះបានដោះស្រាយបញ្ចប់ និងមានរបាយការណ៍ទៅកាន់ថ្នាក់ជាតិចំនួន ១៦ករណី ដោះស្រាយនៅថ្នាក់ខេត្តចំនួន ១៥១ករណី បង្វែរសមត្ថកិច្ចទៅស្ថាប័នតុលាការចំនួន ០២ករណី បង្វែរសមត្ថកិច្ចជូនបណ្តាក្រុង ស្រុក ចំនួន ៤៥ករណី បង្វែរសមត្ថកិច្ចជូនមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ចំនួន ៤៧ករណី។

## ២.៣.លទ្ធផលកម្មសិក្សា

### ២.៣.១.ដំណើរការនៃការដោះស្រាយវិវាទ

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺសំដៅលើវិធីសាស្ត្រ នីតិវិធី បច្ចេកទេស សម្របសម្រួលដោះស្រាយផ្សេងៗរបស់អាជ្ញាធរ ដែលប្រជាពលរដ្ឋបានដាក់ពាក្យស្នើសុំមកកាន់ស្ថាប័នមានសមត្ថកិច្ចទទួលពាក្យបណ្តឹងក្រៅពីការដាក់ពាក្យបណ្តឹងទៅស្ថាប័នតុលាការ។

[8] របាយការណ៍ស្តីពីលទ្ធផលការងាររយៈពេល០១ឆ្នាំ ក្នុងឆ្នាំ ២០២១ របស់ទីចាត់ការអន្តរវិស័យ

រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានការពារសិទ្ធិកម្មសិទ្ធិឯកជនភាពលើអចលនវត្ថុ និងតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ បានចែងអំពីសិទ្ធិ និងករណីកិច្ចពលរដ្ឋខ្មែរ[9] កថាខណ្ឌទី២ថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈ សង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើប្រាស់សិទ្ធសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ប៉ុន្តែការប្រើប្រាស់សិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់។ រដ្ឋធម្មនុញ្ញ បានធានាសិទ្ធិប្រជាពលរដ្ឋក្នុងការប្តឹងបរិហារ ប្តឹងតវ៉ា ប្តឹងទាមទារសំណងជួសជុលការខូចខាតនានា ដែលបណ្តាលមកពីអង្គភាពរដ្ឋ អង្គការសង្គមស៊ីវិល ឬបុគ្គលណាមួយដែលមានបំណងមករំលោភសិទ្ធិបង្កជាបញ្ហាផ្សេងៗ និងទទួលបានដំណោះស្រាយដោយតុលាការឯករាជ្យផងដែរ។ គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈការដកហូតត្រូវធ្វើតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់នឹងបទបញ្ញា បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌[10]។

រដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ទៅលើបញ្ហាគ្រប់គ្រងដីធ្លី ដើម្បីទប់ស្កាត់មិនឱ្យមានបាតុភាពសង្គមទាក់ទងនឹងបញ្ហាទាំងនេះដោយបង្កើតលិខិតបទដ្ឋានគតិយុត្តជាច្រើន ប៉ុន្តែទោះបីជាមានលិខិតបទដ្ឋានគតិយុត្តជាច្រើនក៏ដោយ ក៏វិវាទដីធ្លីនៅតែជាបញ្ហាចោទក្នុងការដោះស្រាយដដែល។ ការមិនស៊ីចង្វាក់នៃបទដ្ឋានគតិយុត្តពីមួយទៅមួយ ក៏ធ្វើឱ្យតួអង្គដែលជាអ្នកដោះស្រាយទំនាស់ដីធ្លីជួបការពិបាកផងដែរ ក្នុងដំណើរកិច្ចប្រតិបត្តិការរបស់ខ្លួនរាល់មានសំណើសុំរបស់ប្រជាពលរដ្ឋ។ ដោយហេតុថា លិខិតបទដ្ឋានគតិយុត្តទាំងនោះ និងនីតិវិធីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងការដោះស្រាយនៅមានកម្រិត រីឯភាពមិនច្បាស់លាស់នៃការកំណត់ដែនសមត្ថកិច្ច និងនីតិវិធីនាំឱ្យការអនុវត្តកាន់តែចោទជាបញ្ហាថែមទៀត។

ការស្វែងរកដំណោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ក្នុងទំនាស់ដែលកើតឡើងមាននៅមូលដ្ឋានរបស់ខ្លួនប្រជាពលរដ្ឋទាំងអស់អាចដាក់ពាក្យស្នើសុំទៅកាន់ដូចខាងក្រោម៖

- ក្រុមប្រឹក្សាឃុំ សង្កាត់៖ ករណីមានទំនាស់កើតឡើងនៅមូលដ្ឋាន ឬតំបន់របស់ប្រជាពលរដ្ឋដែលមានវិវាទ ប្រជាពលរដ្ឋដំហានដំបូងត្រូវដាក់ពាក្យបណ្តឹងនៅកាន់ ឃុំ សង្កាត់ របស់ខ្លួន ដែលមានតួនាទី ដោះស្រាយ សម្របសម្រួល នៅថ្នាក់មូលដ្ឋានមុនពេលករណីនោះបញ្ជូនបន្ត។
- គណៈកម្មការសុរិយោដី៖ មានតួនាទី ពិនិត្យ សិក្សា សម្របសម្រួល ដោះស្រាយ វិវាទដែលកើតមាននៅក្នុង ឬក្រៅតំបន់វិនិច្ឆ័យដែលមិនទាន់ចុះបញ្ជីសុរិយោដី។

[9] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
[10] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៥

- អាជ្ញាធរជាតិដោះស្រាយដីធ្លី៖ ជាយន្តការថ្នាក់ជាតិ បំពេញមុខងារបន្ថែមដល់គណៈកម្មការសុរិយោដី គណៈកម្មការនេះត្រូវបានផ្តល់សិទ្ធត្រួតពិនិត្យលើករណីនានា ដែលផុតពីគណៈកម្មការសុរិយោដី។
- ស្ថាប័នតុលាការ៖ មានសមត្ថកិច្ចដោះស្រាយវិវាទដីទាំងដីមិនទាន់ចុះបញ្ជីសុរិយោដី និងដីបានចុះបញ្ជីសុរិយោដី។

ក្រៅពីយន្តការដោះស្រាយដែលបានរៀបរាប់ខាងលើ ប្រជាពលរដ្ឋអាចដាក់ពាក្យស្នើសុំអន្តរាគមន៍ទៅកាន់ក្រសួង មន្ទីរ ស្ថាប័ន សាមីពាក់ព័ន្ធនានា ដើម្បីជួយសម្រួល និងពន្លឿននីតិវិធីទៅលើការងារដោះស្រាយវិវាទដែលបានស្នើសុំទៅកាន់អាជ្ញាធរមានសមត្ថកិច្ចឱ្យបន្តនីតិវិធីឱ្យបានឆាប់រហ័ស។

ការដោះស្រាយទំនាស់ដីធ្លី គឺត្រូវពិនិត្យទៅលើស្ថានភាពជាក់ស្តែងរបស់ក្បាលដីដែលមានទំនាស់ថា តើដីនោះបានចុះបញ្ជីបណ្ណកម្មសិទ្ធិ ឬមិនទាន់ចុះបញ្ជី? តើគណៈកម្មការ ឬក្រុមការងារត្រូវមានយន្តការបែបណា ដើម្បីដឹកនាំប្រជុំពិនិត្យ ពិភាក្សា សម្របសម្រួល ដោះស្រាយជូនគូភាគីការពារផលប្រយោជន៍ និងធានាភាពត្រឹមត្រូវជូនប្រជាពលរដ្ឋឈានទៅដល់កិច្ចព្រមព្រៀង និងគ្មានការបង្ខិតបង្ខំស្ថិតក្រោមយន្តការឈ្នះ-ឈ្នះជាមូលដ្ឋាន។

### ២.៣.២.ការដោះស្រាយវិវាទតាមរយៈគណៈកម្មការរដ្ឋបាល

គណៈកម្មការរដ្ឋបាល ជាគណៈកម្មការមួយដែលបានបង្កើតឡើង ដើម្បីដឹកនាំការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅតំបន់វិនិច្ឆ័យ។ តួនាទីភារកិច្ចរបស់គណៈកម្មការរដ្ឋបាលនេះ គឺធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតមានក្នុងតំបន់វិនិច្ឆ័យ នៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធជូនដល់ប្រជាពលរដ្ឋ។ នៅពេលដែលតំបន់វិនិច្ឆ័យបានប្រកាសហើយ អភិបាលខេត្ត ក្រុង នៃតំបន់វិនិច្ឆ័យ ត្រូវបានតែងតាំងគណៈកម្មការរដ្ឋបាលសម្រាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យនោះ[11] គណៈកម្មការនេះក៏ទទួលផងដែរ នូវរាល់បណ្តឹងតវ៉ាដោយធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀងរបស់គូភាគី មានន័យថា គណៈកម្មការរដ្ឋបាលអាចធ្វើការកោះអញ្ជើញគូភាគីពាក់ព័ន្ធឱ្យចូលខ្លួនមកបកស្រាយ បំភ្លឺ រាល់ពត៌មានទាំងឡាយណាដែលចាំបាច់ ឬប្រមូលភស្តុតាងឯកសារលិខិតគតិយុត្តនានា ដើម្បីមានមូលដ្ឋានក្នុងការដោះស្រាយ។ បន្ទាប់ពីការប្រមូលផ្តុំព័ត៌មាន ឬឯកសារ រួចរាល់គណៈកម្មការអាចធ្វើការសម្រេចលើវិវាទបានលុះត្រាតែមានការយល់ព្រមឯកភាពពីសំណាក់គូភាគីទាំងសងខាងដែលមានគោលជំហរដោះស្រាយបញ្ចប់វិវាទ។ បន្ទាប់ពីដំណើរនៃការដោះស្រាយវិវាទដីធ្លីក្នុងតំបន់វិនិច្ឆ័យក៏ដូចជាកំណត់បានច្បាស់លាស់នូវប្លង់សុរិយោដី គណៈកម្មការធ្វើការសន្និដ្ឋានផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ និងលើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ជាកម្មសិទ្ធិករ ឬរក្សាទុកជាសម្បត្តិរបស់រដ្ឋ[12]។ ការសន្និដ្ឋានរបស់គណៈកម្មការនេះ ត្រូវស្របទៅតាមស្មារតីរបស់គូភាគីដែលមានគោលជំហរក្នុងការដោះស្រាយ សម្របសម្រួល ក្នុងន័យជារួមមួយ ដែលអាចឈានទៅរកយន្តការឈ្នះ-ឈ្នះ មិនបាត់បង់ប្រយោជន៍ ដល់ភាគីជម្លោះណាមួយឡើយ ប៉ុន្តែប្រសិនគណៈកម្មការ

[11] អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី មាត្រា៣

[12] អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី មាត្រា៣

ខិតខំដោះស្រាយនៅតែមិនអាចសម្របសម្រួលផ្សះផ្សា ឬមានការជំទាស់ពីភាគីណាមួយដែលមិនសុខចិត្តទទួលយក អាជ្ញាធរត្រូវបញ្ជូនសំណុំរឿងទាំងនោះបន្ត។

### ២.៣.៣.ការសម្របសម្រួលតាមរយៈគណៈកម្មការសុរិយោដី

យន្តការនៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការត្រូវបានបង្កើតឡើង ផ្អែកតាមអនុក្រឹត្យលេខ ៤៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ដែលបុគ្គលគ្រប់រូបមានវិវាទអាចដាក់ពាក្យបណ្តឹងស្នើសុំដោយផ្ទាល់ទៅកាន់គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានទីតាំងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ តាមទម្រង់បែបបទនៃពាក្យបណ្តឹងរបស់គណៈកម្មការសុរិយោដី ឬតាមទម្រង់ប្រហាក់ប្រហែល។ គណៈកម្មការសុរិយោដីត្រូវបានបែងចែក ០៣ថ្នាក់ មានដូចខាងក្រោម៖

- គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ
- គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត
- គណៈកម្មការសុរិយោដីថ្នាក់ជាតិ។

#### ក.គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ

គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដឹកនាំដោយប្រធានមួយរូបដែលជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ហើយត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់[13] ព្រមទាំងមានមន្ត្រីនៃការិយាល័យចំណុះជាសេនាធិការក្នុងការជួយសម្របសម្រួល ចាត់ចែង រៀបចំការងារទូទៅប្រចាំថ្ងៃ គណៈកម្មការនេះត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ដែលពាក់ព័ន្ធ និងចាស់ព្រឹទ្ធាចារ្យ ក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុក។ ស្ថិតក្នុងមូលដ្ឋានរបស់បងប្អូនប្រជាពលរដ្ឋករណីវិវាទដែលភាគីបានប្តឹងជំទាស់តវ៉ាទាមទារស្វែងរកភាពយុត្តិធម៌ការពារផលប្រយោជន៍របស់ខ្លួន ដែលកើតឡើងមួយចំនួន មេភូមិជាបុគ្គលដែលភាគីវិវាទបានទាក់ទងមុនដំបូងគេបង្អស់ ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចជួយសម្របសម្រួល ដោះស្រាយ និងកោះអញ្ជើញភាគីមកធ្វើការសួរនាំអំពីប្រវត្តិសាវតាដី ភស្តុតាង លិខិត ឯកសារនានាដោយផ្ទាល់ទាក់ទងនឹងវិវាទដែលភាគីដើមបណ្តឹងបានស្នើសុំ។ ក្នុងន័យនេះ ការប្រមូលផ្តុំព័ត៌មាន និងក្តោបក្តាប់សភាពការណ៍ជាក់ស្តែងរវាងគូភាគី ជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងដំណើរការឈានទៅរកការស្វែងរកគោលជំហររួមក្នុងការដោះស្រាយបញ្ចប់វិវាទនីមួយៗ ដោយធ្វើជាអ្នកធានាដឹកនាំកិច្ចចរចាអព្យាក្រឹត្យម្នាក់ប្រគល់ជូនភាគីមានឱកាសនិយាយទៅកាន់គ្នាទៅវិញទៅមក ឱ្យយល់ពីគោលគំនិតរៀងៗខ្លួន បន្ធូរបន្ថយការប៉ះទង្គិចផ្លូវអារម្មណ៍ ទាក់ទាញទំនុកចិត្តរបស់ភាគីដើម្បីឱ្យភាគីហ៊ានបញ្ចេញមតិផ្ទាល់ខ្លួន។ ឆ្លងតាមការពិនិត្យជាក់ស្តែងក្នុងមូលដ្ឋាន ឬសហគមន៍

[13] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា៥

នានាក្នុងព្រះរាជាណាចក្រកម្ពុជា ឃើញថា វិវាទដីធ្លីមួយចំនួនភាគច្រើនកើតមានត្រូវបានលោកមេឃុំ សង្កាត់ រួមក្រុមការងាររដ្ឋបាលឃុំ សង្កាត់ ប្រើយន្តការ ទាក់ទងកោះអញ្ជើញគូភាគីមកប្រជុំ ពិនិត្យ ពិភាក្សា សម្របសម្រួល និងដោះស្រាយបញ្ចប់ក្នុងកម្រិតរបស់រដ្ឋបាលឃុំ សង្កាត់ ប្រសិនបើការសម្របសម្រួលមិនមានលទ្ធភាព ទើបបញ្ជូនសំណុំរឿងបន្តមកកាន់គណៈកម្មការសុរិយោដីក្រុង ស្រុក ខណ្ឌ។

គណៈកម្មការសុរិយោដីក្រុង ស្រុក ខណ្ឌ មានតួនាទី ភារកិច្ចដោះស្រាយ សម្របសម្រួល លើវិវាទដីធ្លីណាមួយដែលកើតមានឡើងក្រៅតំបន់វិនិច្ឆ័យ ការសម្របសម្រួលនេះត្រូវបានអនុវត្តតាមទំនៀមទម្លាប់ប្រពៃណី និងបច្ចេកទេស រាល់កិច្ចប្រជុំដោះស្រាយ សម្របសម្រួល ត្រូវមានការចូលរួមពីសំណាក់មន្ត្រីជំនាញគ្រប់ផ្នែកនៃផែនការិយាល័យដែលខ្លួនមានភារកិច្ចទទួលអនុវត្ត។ ក្នុងជំហាននៃដំណាក់កាលការដោះស្រាយគណៈកម្មការសុរិយោដីត្រូវមានកាតព្វកិច្ច ពន្យល់ ណែនាំ អំពីនីតិវិធីសម្របសម្រួលដើម្បីឱ្យភាគីអាចសម្រេច ព្រមព្រៀង ឬប្រានចោលជាពិសេសព្យាយាមបើកជំហរឱ្យភាគីមានការចរចា ទោះការចរចានេះដើម្បីប្រយោជន៍ខ្លួន ឬក្នុងនាមអ្នកតំណាងក៏ដោយ។ ការចរចា ជាដំណើរការនៃការជួបពិភាក្សាគ្នារវាងគូភាគី បង្ហាញពីគោលជំហររៀងខ្លួនដាក់ជូន ឬពិចារណាលើសំណើផ្សេងៗផងដែរ រហូតដល់សំណើគូភាគីអាចឈានដល់ចំណុចមួយដែលអាចមានដំណោះស្រាយដើម្បីបញ្ចប់វិវាទ។ នីតិវិធីនៃការចរចា ជាជម្រើសមួយដ៏សាមញ្ញបំផុតនៃដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅទូទាំងសកលលោក ដែលយើងពិនិត្យឃើញថា គេនិយមលើកយកមកអនុវត្ត ការចរចានេះពិតជាមានសារៈប្រយោជន៍ណាស់ ដែលអាចដោះស្រាយទាំងវិវាទតូច ធំ ហើយជាដំណើរផ្សះផ្សាពីរឿងស្មុគស្មាញបំផុតប្រែក្លាយជារឿងធម្មតា ព្រោះវាជាទម្រង់ នៃការប្រាស្រ័យទាក់ទងរវាងមនុស្ស និងមនុស្សដែលច្បាប់ធម្មជាតិបានកំណត់។ ការជួបចរចាអាចធ្វើឡើងបានតាមរយៈវិធីជាច្រើនដូចជា ផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ផ្ទាល់រវាងគូភាគី ឬអាចតាមរយៈតំណាង សំបុត្រលក្ខណៈផ្លូវការ និងតាមអ៊ីម៉ែល។ ប៉ុន្តែទោះជាយ៉ាងណាក្តី ក្នុងដំណើរការសម្របសម្រួលដោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវស៊ើបអង្កេតរួមមាន ការបញ្ជាក់អំពីទីតាំងនៃក្បាលដីដែលមានវិវាទ គូភាគីពាក់ព័ន្ធអំពីកម្មវត្ថុនៃវិវាទ ការប្រមូលឯកសារដែលមានចម្លើយរបស់សាក្សី និងព័ត៌មានទាក់ទងនឹងក្បាលដីមានវិវាទ។ គណៈកម្មការសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវថតចម្លង និងបញ្ជាក់លើឯកសារចម្លងនោះសំរាប់ទុកជាសំណុំរឿង និងប្រគល់ច្បាប់ដើមឱ្យភាគីវិវាទ។ គណៈកម្មការសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវកសាង និងបញ្ជូនឯកសារស៊ើបអង្កេតទៅក្នុងសំណុំរឿងវិវាទ[14]។

ឆ្លងតាមការបកស្រាយខាងលើ គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអាជ្ញាធរសុរិយោដី ដំបូងដែលទទួលយកយករឿងវិវាទមកដោះស្រាយ ប៉ុន្តែយោងតាមមាត្រា ៥ វាក្យខ័ណ្ឌទី១ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/ប.ក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី គណៈកម្មការនេះត្រូវបានដឹកនាំដោយលោកប្រធានមួយរូបជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ជាហេតុធ្វើឱ្យ

[14] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា៨

ដំណើរការដោះស្រាយវិវាទទាំងអស់មិនសូវទទួលបានជោគជ័យក្នុងការដោះស្រាយ សម្របសម្រួល។ នៅរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះគណៈកម្មការនេះត្រូវបានប្តូរមកឱ្យលោកអភិបាលក្រុង ស្រុក ខណ្ឌ វិញជាអ្នកទទួលបន្ទុកបំពេញការងារចាត់ចែងអនុវត្ត ដូច្នេះ ការផ្លាស់ប្តូរនេះជាកត្តារួមផ្សំមួយផ្នែកក្នុងដំណើរការដោះស្រាយ ព្រោះគណៈកម្មការក៏មានឥទ្ធិពល រីឯគូភាគីវិវាទក៏មានការគោរពកោតខ្លាច។

**ខ.គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត**

គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត មានសមាសភាពដូចជា គណៈអភិបាល ឬគណៈអភិបាលរងរាជធានី ខេត្ត ជាប្រធាន និងលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ជាសមាជិក តួនាទីភារកិច្ចនេះត្រូវបានកំណត់ តែងតាំង ប្រកាសរួមដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត អាចអញ្ជើញតំណាង ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញពាក់ព័ន្ធឱ្យចូលជាសមាជិកអាដហុក[15]។

គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត មានភារកិច្ចសម្របសម្រួលវិវាទមានក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/ប.ក ចែងថា បន្ទាប់ពីការស៊ើបអង្កេត ប្រសិនបើឃើញថា វិវាទមិនអាចត្រូវបានដោះស្រាយដោយសមធម៌នៅថ្នាក់ក្រុង ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬតាមសំណើរបស់ភាគីវិវាទទាំងសងខាងចំពោះករណីដូចតទៅះ

- ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ
- ភាគីម្ខាងនៃវិវាទ គឺជាអាជ្ញាធរមានឋានៈខ្ពស់
- ករណីមានវិវាទពាក់ព័ន្ធ និងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ
- វិវាទដែលពាក់ព័ន្ធនឹងដីសាធារណៈរដ្ឋ។

ក្នុងចំណុចនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតច្បាប់ដោយបែងចែក តួនាទី ភារកិច្ច មុខងារ យ៉ាងច្បាស់លាស់អំពីឋានានុក្រម និងដែនសមត្ថកិច្ច នៃការដោះស្រាយរបស់គណៈកម្មការសុរិយោដីរាជធានី ខេត្ត។ ទោះជាយ៉ាងណាក្តី ក្នុងដំណើរនីតិវិធីនៃការដោះស្រាយវិវាទនោះ ក៏តម្រូវឱ្យមានក្រុមការងារស៊ើបអង្កេតផងដែរ ក្នុងនីតិវិធីនៃការស៊ើបអង្កេតនេះ គណៈកម្មការសុរិយោដីមានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ចំណែកឯមន្ត្រីដែលមានតួនាទី និងបំពេការងារនៅលេខាធិការដ្ឋាននោះ ជាមន្ត្រីសាធារណៈតែងតាំងដោយរដ្ឋមន្ត្រីក្រសួង

[15] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា១២

រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី តាមសំណើរបស់គណៈកម្មការសុរិយោដី។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត មានមុខងារ និងភារកិច្ចដូចតទៅះ

- ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាល់បណ្តឹងពាក់ព័ន្ធនឹងវិវាទដីធ្លី
- ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត
- ធ្វើរបាយការណ៍ អំពីលទ្ធផលនៃការស៊ើបអង្កេត
- រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត
- ធ្វើកំណត់ហេតុ អំពីដំណើរការសម្រុះសម្រួល និងធ្វើរបាយការណ៍អំពីលទ្ធផល នៃការសម្រុះសម្រួល
- បញ្ជូនកំណត់ហេតុ និងរបាយការណ៍ទាំងនេះទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្នុងករណីការសម្រុះសម្រួលបានសំរេច ត្រូវផ្ញើរលទ្ធផលនៃការសម្រុះសម្រួលទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ[16]។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់ ឬសមត្ថកិច្ចណាដែលរាជរដ្ឋាភិបាលប្រគល់ឱ្យស្ថាប័នផ្សេងទៀត[17]។

វិវាទដែលដោះស្រាយមិនទាន់បានសម្រេចនៅគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញ និងរបាយការណ៍សម្រុះសម្រួលទៅគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត[18]។ ក្នុងរយៈពេល ៦០ថ្ងៃ ក្រោយពីទទួលបានសំណុំរឿងវិវាទ គណៈកម្មការនេះត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត និងគូភាគីដោយមានការចូលរួមពីអាជ្ញាធរដែនដី ឬមន្ត្រី ជុំវិញរាជធានី ខេត្ត ពាក់ព័ន្ធនានាចូលរួមដើម្បីសម្រុះសម្រួលវិវាទ។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋបាលដំបូង ភាគីវិវាទត្រូវលើកសំណើ និងការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលសំរាប់វិវាទនោះ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីវិវាទ និងកំណត់ពេលវេលាសម្រាប់ឱ្យភាគីបង្ហាញភស្តុតាងបន្ថែមនានា និងពេលវេលាសំរាប់សម្រុះសម្រួលវិវាទ[19]។

[16] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា១៤

[17] អនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ មាត្រា២

[18] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៣០

[19] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៣០

ក្រោយពីមានការកោះអញ្ជើញគូភាគីវិវាទមកចូលក្នុងអង្គប្រជុំតាមពេលវេលាកំណត់ណាមួយ របស់គណៈកម្មការនេះ និងបន្ទាប់ពីបានដឹងអំពីសាវតា ប្រវត្តិដីតាមរយៈរបាយការណ៍ស៊ើបអង្កេត ព្រមទាំងបានកំណត់អង្គហេតុផ្សេងៗរបស់លេខាធិការដ្ឋានដែលបានរៀបចំឡើងរួចរាល់មកគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវសម្រុះសម្រួលជាមួយគូភាគីវិវាទទៅតាមគោលជំហររៀងៗខ្លួនដោយប្រកាន់យកភាពសុចរិត យុត្តិធម៌ និងត្រឹមត្រូវ ក្នុងនាមជាអាជ្ញាធរជាបន្ទាន់តាមលទ្ធភាពដែលអាចធ្វើទៅបាន មួយវិញទៀត គណៈកម្មការនេះពុំមានសិទ្ធិសម្រេច អនុម័តលើករណីទំនាស់ដីធ្លីណាមួយឡើយ ប៉ុន្តែក៏អាចបញ្ចប់វិវាទបាន ក្នុងករណីភាគីវិវាទទាំងអស់បានព្រមព្រៀងគ្នាជាឯកច្ឆន្ទ[20]។ កត្តាទាំងនេះ ជាធាតុរួមផ្សំដែលអាចបង្ហាញឱ្យយើងឃើញថា គណៈកម្មការនេះពុំមានដែនសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការសម្រេចបញ្ចប់វិវាទណាមួយឡើយ គណៈកម្មការនេះមានអំណាចមួយដែលអាចនិយាយបានថា អញ្ជើញភាគីពាក់ព័ន្ធមកមានមតិចូលរួមក្នុងអង្គប្រជុំ ស្វែងរកការដោះស្រាយ អនុវត្តតាមទម្លាប់ប្រពៃណី និងបច្ចេកទេសសុរិយោដី ដើម្បីឱ្យគូភាគីអាចយល់ដឹងអំពីបញ្ហារបស់ខ្លួន ហើយបន្តធ្វើការផ្សះផ្សារ សម្របសម្រួល តាមឆន្ទះរបស់ម្ចាស់សំណើ។ ប៉ុន្តែក្នុងករណីប្រសិនបើ ក្នុងការសម្រុះសម្រួលអាចសម្រេចបាន គណៈកម្មការសុរិយោដីថ្នាក់រាជធានីខេត្ត ត្រូវផ្ញើលទ្ធផលជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ដើម្បីចាប់ផ្តើមដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួច[21]។ ទន្ទឹមនេះ ប្រសិនបើការដោះស្រាយមិនអាចដោះស្រាយបានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវបញ្ជូនសំណុំរឿងវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការសម្រុះសម្រួល ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីបន្តនីតិវិធីដោះស្រាយ។

### គ.គណៈកម្មការសុរិយោដីថ្នាក់ជាតិ

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិសម្រេចលើវិវាទទាំងឡាយដែលស្ថិតនៅក្រៅតំបន់វិនិច្ឆ័យ ដែលមិនអាចដោះស្រាយបានដោយគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់រាជធានីខេត្ត រាល់វិវាទដែលកើតមានឡើងនៅក្នុងតំបន់វិនិច្ឆ័យដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាល[22]។ យោងតាមមាត្រា ១៨ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/ប.ក ចែងថា គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមត្ថកិច្ចចេញសេចក្តីសម្រេចលើវិវាទដីភោគៈ ដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោម ឬគណៈកម្មការរដ្ឋបាលពុំអាចសម្រុះសម្រួលបានដូចមានចែងក្នុងមាត្រា ១៦ និងវិវាទដែលចែងក្នុងចំណុចទី២ មាត្រា ៣ អនុក្រឹត្យខាងលើ។ គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន
- រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ ជាសមាជិក
- រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

[20] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា១៥

[21] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា១៦

[22] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៣៨

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា[23]។ គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានយុត្តាធិការពេញលេញក្នុងការធ្វើសេចក្ដីសម្រេចទទួលស្គាល់ភាគី ឬកម្មសិទ្ធិករស្របច្បាប់[24]។ អំពីចក្ខុវិស័យ និងការសំឡឹងមើលឃើញនូវភាពខ្វះចន្លោះក៏ដូចជាដែនសមត្ថកិច្ចរបស់អាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការសម្របសម្រួលវិវាទដែលកើតមានឡើង ជាពិសេសវិវាទទាំងឡាយណាដែលអាជ្ញាធរមូលដ្ឋានមិនទាន់បានដោះស្រាយបញ្ចប់ ទើបរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា បង្កើតគណៈកម្មការកម្មការសុរិយោដីថ្នាក់ជាតិ ដែលមានលេខាធិការដ្ឋានមួយជាសានាធិការ និងជាអង្គភាពស៊ើបអង្កេត។ លេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិមានតួនាទីដូចតទៅៈ

- ទទួលសំណុំរឿងពីគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត និងរាល់ពាក្យបណ្ដឹងទាក់ទងនឹងវិវាទដីធ្លី
- ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត
- រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ
- ធ្វើកំណត់ហេតុអំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការដោះស្រាយ
- បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្ដឹងតវ៉ាលើសេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទៅតុលាការ
- រៀបចំ និងតម្កល់ទុកឯកសារ។[25]

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋានមួយជាសានាធិការ ដូចជាគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលមានតួនាទីដូចគ្នាក្នុងការស៊ើបអង្កេត និងការចុះបញ្ជីសំណុំរឿងវិវាទទាំងឡាយណាដែលបានកើតឡើង។ នៅពេលបានបញ្ចប់ការស៊ើបអង្កេតលើអង្គហេតុ ត្រួតពិនិត្យឯកសារ លិខិតបទដ្ឋានគតិយុត្ត និងកំណត់ហេតុផ្លូវការនៃវិវាទ ឬនៅពេលផ្សេងទៀតក្នុងអំឡុងពេលធ្វើការពិនិត្យវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចសំរេចធ្វើការសម្រុះសម្រួលវិវាទបន្ថែមទៀត[26]។ ទោះជាយ៉ាងណាក្ដី គណៈកម្មការខាងលើមានសិទ្ធិសម្រេចលើករណីវិវាទដែលមិនទាន់អាចសម្របសម្រួល ប៉ុន្តែមុនពេលធ្វើការសម្រេច គណៈកម្មការមួយនេះនៅតែបន្តព្យាយាមដោះស្រាយបញ្ចប់ ដោយពិនិត្យទៅលើគោលជំហរ ឆន្ទៈ របស់គូភាគីតាមរយៈរបាយការណ៍របស់គណៈកម្មការសុរិយោដីថ្នាក់ក្រោមជាតិកន្លងមក ដើម្បីឱ្យភាគីអាចទទួលយកបានទាំងអស់គ្នាក្នុងន័យធានាបរិយាកាសសប្បាយរីករាយ ស្និទ្ធស្នាល ដោយអនុវត្តគោរពតាមយន្តការឈ្នះ-ឈ្នះ។

---

[23] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា១៧

[24] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា២០

[25] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា១៩

[26] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៤១

ផ្អែកតាមការសម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រសិនបើការសម្រុះសម្រួលមិនបានសម្រេច ប្រធានគណៈកម្មការសុរិយោដីជាតិ ត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការធ្វើសវនាការដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចកោះអញ្ជើញតំណាងក្រសួង និងស្ថាប័នពាក់ព័ន្ធអោយចូលជាសមាជិកអាដហុកដើម្បីដោះស្រាយ[27]។ រាល់កិច្ចប្រជុំ ឬសវនាការដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិចាត់វិធានការផ្លូវការទាក់ទងនឹងវិវាទត្រូវបើកចំហរជាសាធារណៈ[28]។ ក្នុងន័យនេះ រាល់កិច្ចប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ កន្លងមកឃើញថា ត្រូវបានរៀបចំឡើងដោយចំហរមិនត្រូវបានហាមឃាត់ ឬប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ឬបុគ្គលណាមួយឱ្យចូលរួមនោះទេ ទោះបីជាក្នុងវិវាទនោះមានភាគីដែលមិនមានផលប្រយោជន៍ក្នុងរឿងនោះក៏ដោយ សមាជិក សមាជិកា អាចមានសិទ្ធិអង្គុយក្នុងអង្គប្រជុំស្តាប់ការមានមតិឆ្លងឆ្លើយគ្នារវាងគូភាគី និងគណៈ-កម្មការប្រធានអង្គប្រជុំ។ លើកលែងតែ ការប្រជុំសម្រាប់ការសម្រុះសម្រួលដែលអាចធ្វើឡើងជាមួយវិវាទដោយឡែកពីគ្នា គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអញ្ជើញភាគីដែលមានប្រយោជន៍ទាំងអស់ឱ្យចូលរួមកិច្ចប្រជុំ និងសវនាការទាក់ទងទៅនឹងវិវាទរបស់ពួកគេ។ សេចក្តីអញ្ជើញ ត្រូវបញ្ជូនទៅឱ្យភាគីយ៉ាងហោចណាស់ ១៥ថ្ងៃ នៃថ្ងៃមុនពេលបើកកិច្ចប្រជុំ ឬសវនាការ[29] ក្នុងចំណុចនេះ ការរៀបចំលិខិតអញ្ជើញកោះហៅគូភាគី អ្នកពាក់ព័ន្ធ ពិសេសសាក្សីដឹងឮ ការជូនដំណឹងមុនថ្ងៃនៃកិច្ចប្រជុំចាប់ផ្តើមជាការឱ្យភាគីត្រៀមរៀបចំខ្លួន ក៏ដូចជាស្វែងរកប្រមូលឯកសារ ភស្តុតាងនានា ដើម្បីធានាថា រាល់កិច្ចប្រជុំសម្រុះសម្រួលទាំងឡាយ ត្រូវបានចាប់ផ្តើមដោយមិនមានការខកខានពីសំណាក់ភាគីណាមួយដែលអវត្តមាន ស្របតាមស្មារតីអង្គប្រជុំដែលតម្រូវឱ្យភាគីចូលរួមតាមពេលវេលាដែលបានកំណត់។

ករណីវិវាទទាំងឡាយណាដែលតម្រូវឱ្យមានការសម្រេច ឬដំណើរការដោះស្រាយជាបន្ទាន់ ដូចជាករណីមានការគំរាមគំហែង ឬការភ័យខ្លាចសមហេតុផលកើតឡើងពីការបង្កអគ្គីភ័យ ការប្រើកំលាំង ឬការបំភិតបំភ័យ ភាគីវិវាទអាចស្នើទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យចាត់វិធានការបណ្តោះអាសន្ន ដើម្បីការពារផលប្រយោជន៍របស់ភាគីនៅពេលដែលវិវាទកំពុងធ្វើការដោះស្រាយ។ ក្នុងស្ថានភាពនេះ ភាគីអាចប្តឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យចេញសេចក្តីសម្រេចបណ្តោះអាសន្ន ដើម្បីធ្វើឱ្យស្ថានការណមានស្ថេរភាពរហូតដល់មានការស៊ើបអង្កេត និងសេចក្តីសម្រេចរបស់គណៈកម្មការនេះ។ សេចក្តីសម្រេចបណ្តោះអាសន្នត្រូវមានខ្លឹមសារជាការរក្សាស្ថានភាពដដែល[30]។ សេចក្តីសម្រេច ជាវិធានការរដ្ឋបាលនៃការចាត់ចែងជាបណ្តោះអាសន្នវត្ថុដែលជាកម្មវត្ថុនៃវិវាទមានគោលបំណងរក្សាស្ថានភាពដើមនៃកម្មវត្ថុនោះ ដើម្បីធានានូវការប្រើប្រាស់សិទ្ធិតាមរយៈការអនុវត្តដោយបង្ខំបំបាត់ចោលជាបណ្តោះអាសន្ននូវហានិភ័យដែលអាចកើតឡើង និងភាពអស្ថេរភាព ប៉ុន្តែមិនមែនដើម្បីធានានូវការប្រើប្រាស់សិទ្ធិនាពេលអនាគតឡើយ។ ក្នុងដំណើរការដោះស្រាយនេះគូភាគីអាចជ្រើសរើសបុគ្គលម្នាក់តាមជំរើស

[27] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៤០
[28] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៤៣
[29] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៤៤
[30] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៣៩

របស់ខ្លួនផ្ទាល់ ឱ្យតំណាងខ្លួននៅក្នុងរាល់ដំណើរការ នៃរឿងវិវាទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ[31] ការជ្រើសរើសតំណាងក្នុងដំណើរការការពារក្តីនេះ តម្រូវឱ្យរៀបចំលិខិតមួយជាលាយលក្ខណ៍អក្សរជាក់លាក់ក្នុងការប្រគល់ភារៈកិច្ចរបស់ភាគី ដើម្បីឱ្យអ្នកតំណាងមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេច និងដោះស្រាយ។ អ្នកតំណាងក្តីក្នុងរឿងវិវាទអាចពិភាក្សា ណែនាំ ពាក់ព័ន្ធផ្នែកច្បាប់ ប្រសិនបើមានការស្នើសុំពីសំណាក់បុគ្គលដែលខ្លួនត្រូវតំណាង ប៉ុន្តែត្រូវតែមានការគោរព និងកំណត់នូវដែនសមត្ថកិច្ចរបស់ខ្លួន ដោយធានាថាមិនបំពានវិធាននៃដំណើរការរឿងវិវាទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ គណៈកម្មការសុរិយោដីថ្នាក់ជាតិពេលបើកសវនាការ មិនត្រូវបានតម្រូវឱ្យគោរពតាមវិធានភស្តុតាង ឬនីតិវិធីផ្លូវការទេ ប៉ុន្តែត្រូវធានាឱ្យភាគីទាំងអស់មានឱកាសបង្ហាញសក្ខីកម្ម និងភស្តុតាងរបស់ខ្លួនដោយយុត្តិធម៌ និងសមធម៌[32] ក្នុងចំណុចនេះ ភស្តុតាងដែលភាគីដាក់មកកាន់គណៈកម្មការភាគីនៅតែធ្វើការបដិសេដបាន។ យ៉ាងណាមិញ ប្រសិនបើមិនមានការជំទាស់នឹងភស្តុតាង និងលិខិតបទដ្ឋានគតិយុត្តនានាផ្សេងទៀត ដែលភ្ជាប់មកជាមួយនឹងពាក្យបណ្តឹងនោះទេ គណៈកម្មការសុរិយោដីថ្នាក់ជាតិមានសិទ្ធិធ្វើការសន្និដ្ឋាន ដើម្បីចេញសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចរបស់គណៈកម្មការនេះ ក្លាយជាសេចក្តីសម្រេចស្ថាពរនៅក្រោយរយៈពេល ៣០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចនោះត្រូវបានបញ្ជូនទៅដល់ភាគីវិវាទទាំងអស់ លើកលែងតែករណីមានការប្តឹងទៅតុលាការ ឬមានការស្នើសុំពិនិត្យឡើងវិញដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ[33]។ មុនសេចក្តីសម្រេចបានចូលជាធរមាន ភាគីមានសិទ្ធិស្នើសុំឱ្យគណៈកម្មការពិនិត្យឡើងវិញរាល់ការសម្រេចនានានូវបញ្ហាពាក់ព័ន្ធ មុនរយៈពេលដែលគណៈកម្មការបានកំណត់ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្តឹងទៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ[34]។ បណ្តឹងជំទាស់ត្រូវដាក់ជូនទៅតុលាការក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចជាលាយ-លក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ[35] នៅពេលដែលសេចក្តីសម្រេចមានសុពលភាពអាចអនុវត្តបាន គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបញ្ជូនសេចក្តីសម្រេចនេះទៅឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដើម្បីធ្វើការអនុវត្តនីតិវិធីចុះបញ្ជី។

## ២.៤.លក្ខណៈការខារបច្ចេកទេស

### ក.ចរន្ត ឬវគ្គនៃដំណើរនៃការដោះស្រាយវិវាទដីធ្លី

ចំពោះករណីវិវាទទាំងឡាយណា ដែលបងប្អូនប្រជាពលរដ្ឋបានកើតមានឡើងជួបប្រទះ ស្ថិតនៅក្នុងមូលដ្ឋាន ឬភូមិសាស្ត្រនានានៅក្នុងខេត្តកណ្តាល បងប្អូនប្រជាពលរដ្ឋអាចដាក់ពាក្យស្នើសុំអន្តរាគមន៍មកកាន់រដ្ឋបាលខេត្ត ដើម្បីស្នើសុំអាជ្ញាធរមានសមត្ថកិច្ច អង្គភាពជំនាញពាក់ព័ន្ធចុះពិនិត្យ សិក្សា ស្រាវជ្រាវ ដោះស្រាយ តាមរយៈការ

[31] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៤៥

[32] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៤៧

[33] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៤៨

[34] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា២៣

[35] ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី ប្រការ៥០

បញ្ជូនឯកសារចូលការិយាល័យរបៀប និងឯកសារ ដើម្បីរៀបចំបំពេញបែបបទធ្វើកំណត់បង្ហាញប្រគល់ភារៈកិច្ចបន្តជូនទៅកាន់ការិយាល័យ ឬអង្គភាពជំនាញ ដើម្បីធ្វើការពិនិត្យ និងស្រាវជ្រាវ លើកជាយោបល់ជូនថ្នាក់ដឹកនាំនៃដំណើររឿង និងផ្តល់នីតិវិធីដោះស្រាយបន្តជូនលោកនាយកទីចាត់ការ នាយករដ្ឋបាល អភិបាលរងខេត្តទទួលបន្ទុក និងអភិបាលខេត្ត។ ក្រុមការងារដោះស្រាយវិវាទនឹងកោះអញ្ជើញគូភាគីមកដោះស្រាយ សម្របសម្រួល និងបូកសរុបរបាយការណ៍អំពីលទ្ធផលជូនឯកឧត្តមអភិបាលខេត្តជ្រាបជារបាយការណ៍ និងស្នើសុំអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់។ ក្រោយពីក្រុមការងារបូកសរុបរៀបចំរបាយការណ៍ជូនទៅកាន់អភិបាលខេត្តដើម្បីជ្រាប ក្រុមការងារដោះស្រាយវិវាទពុំមានសិទ្ធិ និងករណីកិច្ចក្នុងការសម្រេចដោយឯកច្ឆ័នលើបញ្ហាវិវាទទាំងនោះបានឡើយ។

## ២.៥.ចំណុចខ្លាំង និងភាពនុវត្តភាព

### ក.ចំណុចខ្លាំង

- ទីចាត់ការអន្តរវិស័យ ជាបណ្តុំការិយាល័យជំនាញក្នុងការសម្របសម្រួល និងដោះស្រាយនូវសាច់រឿងចម្រុះជាច្រើនជូនស្ថាប័ន និងជូនប្រជាពលរដ្ឋដែលបានដាក់សំណើសុំសម្របសម្រួល ដោះស្រាយ។
- មន្ត្រីក្នុងទីចាត់ការមានភាពសកម្ម ឆន្ទៈម្ចាស់ការ មនសិការវិជ្ជាជីវៈ គណនេយ្យភាព និងឯកភាពផ្ទៃក្នុងចំពោះការបំពេញការងារប្រចាំថ្ងៃក្នុងទីចាត់ការ។
- ការរៀបចំឯកសារត្រូវបានរៀបចំទុកដាក់តាមលំដាប់លំដោយ និងតាមលំហូររបស់ឯកសារចេញ-ចូល ពិសេសមានការបែងចែកសម្រាប់មន្ត្រីដែលទទួលបន្ទុករៀបចំងាយស្រួលស្វែងរក។
- បរិយាកាសការងារមានភាពស្និតស្នាល ការិយាល័យនីមួយៗមានជាសុខភាពបំពាក់ដោយគ្រឿងបរិក្ខារទំនើបទាន់សម័យដូចជា ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនថតចម្លង(សខ្មៅ ខូល័រ) ព្រីនធើរ កុំព្យូទ័រ ទូរក្សាទុកឯកសារ។
- ការអនុវត្តការងារមានភាពឆាប់រហ័ស ដោយមន្ត្រីក្នុងទីចាត់ការបានប្រើប្រាស់នូវបណ្តាញប្រព័ន្ធទំនាក់ទំនងផ្សេងៗ ដើម្បីបញ្ជូនព័ត៌មានទៅវិញទៅមកបានទាន់ពេលវេលា។
- ភាពស្និទ្ធស្នាល និងការបើកចិត្តទូលាយក្នុងការផ្តល់មតិណែនាំពាក់ព័ន្ធជាមួយការអនុវត្តការងាររវាងលោកនាយក លោក-លោកស្រីនាយករងទីចាត់ការ និងមន្ត្រីចំណុះការិយាល័យដទៃទៀត។

### ខ.ភាពនុវត្តភាព

- មន្ត្រីនៅក្នុងទីចាត់ការទាំងអស់ក៏ដូចជាស្ថិតក្រោមដំបូលរបស់រដ្ឋបាលខេត្តកណ្តាលទាំងមូល ទទួលបានឱកាសទទួលបានចំណេះដឹង វគ្គបណ្តុះបណ្តាល វគ្គបំប៉ន ពាក់ព័ន្ធជាមួយកិច្ចការងារបែបបទរដ្ឋបាល ដែលមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តបន្ថែមលើជំនាញរបស់ខ្លួនដែលកំពុងអនុវត្តប្រចាំថ្ងៃ។
- ទទួលបានការលើកទឹកចិត្តពីថ្នាក់ដឹកនាំដូចជា ការផ្តល់ជូននូវថ្លៃសាំង និងប្រាក់រង្វាន់តាមសន្ទស្សន៍ប្រចាំខែចំពោះមន្ត្រីដែលបានបំពេញតួនាទីភារកិច្ចល្អ។
- មន្ត្រីដែលមានសមត្ថភាពនឹងទទួលបានឱកាសកាន់នូវមុខតំណែងនានាតាមកម្រិតរបស់គាត់។

## ២.៦.បញ្ហាប្រឈម និងសំណូមពរ

### ក.បញ្ហាប្រឈម

- បញ្ហាគុណភាពមន្ត្រីនៅតែជាបញ្ហាប្រឈមមួយ ដែលទីចាត់ការអន្តរវិស័យខ្វះមន្ត្រីតាក់តែងលិខិតរដ្ឋបាល និងរៀបចំសារជូនពរ លិខិតចែករំលែកទុក្ខនានា។
- ការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់ កំពុងខ្វះប្រធានការិយាល័យជាហេតុរាល់បន្ទុកការងារទាំងអស់ក្នុងការិយាល័យ ត្រូវធ្លាក់លើលោកនាយករងទីចាត់ការអន្តរវិស័យ ជាអ្នកពិនិត្យតាមដានបណ្ដោះអាសន្ននឹងរងចាំប្រធានការិយាល័យថ្មីចូលមកកាន់តំណែង។
- បញ្ហាមន្ត្រីមួយចំនួនមកបំពេញការងារមិនទៀតទាត់ស្របតាមច្បាប់ដែលបានកំណត់ ក្នុងការបែងចែងតួនាទីភារកិច្ចមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។

### ខ.សំណូមពរ

ខ្ញុំបាទសូមកោតសរសើរ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់របស់សាលាខេត្តកណ្ដាល ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន និងប្រកបដោយគណនេយ្យភាពទាំងចំពោះប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលកម្ពុជា។ ម្យ៉ាងទៀត នៅក្នុងទីចាត់ការអន្តរវិស័យដែលមានការិយាល័យចំណុះទាំង ០៣ ជាសេនាធិការ ដែលបានជួយអនុគ្រោះដល់ខ្ញុំបាទក្នុងការចុះកម្មសិក្សា និងសរសេររបាយការណ៍មួយនេះឡើងទទួលបានលទ្ធផល និងចេញជាផ្លែផ្កា។ ទន្ទឹមនេះ ខ្ញុំសូមសំណូមពរដល់រដ្ឋបាលខេត្តកណ្ដាល បន្តធ្វើការពង្រឹងសមត្ថភាពមន្ត្រីបន្ថែមទៀតលើកិច្ចការបែបបទរដ្ឋបាល ពិសេសពន្លឿននីតិវិធីនៃការដោះស្រាយវិវាទទាំងឡាយណាដែលប្រជាពលរដ្ឋបានដាក់ពាក្យស្នើសុំមកកាន់រដ្ឋបាលខេត្តឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាព ដើម្បីធានាការរស់នៅរបស់ប្រជាពលរដ្ឋកាន់តែមានភាពប្រសើរឡើងប្រកបដោយសុភមង្គល សុខដុមរមនា ទាំងក្នុងគ្រួសារ និងសហគមន៍ឆ្ពោះទៅរកវឌ្ឍនភាព និងវិបុលភាពដ៏រុងរឿង។ ទោះបីជានៅមានភាពខ្វះចន្លោះនៅចំណុចផ្សេងៗយ៉ាងណាក្ដីក្នុងការបំពេញកិច្ចការងារប្រចាំថ្ងៃ ប៉ុន្តែស្ថិតក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយសាមគ្គីភាព តម្លាភាព និងការឯកភាពផ្ទៃក្នុងរបស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់របស់រដ្ឋបាលខេត្តឃើញថា គ្រប់ការងាររបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ផែនការអភិវឌ្ឍមូលដ្ឋាន សេវាកម្មសាធារណៈ សណ្ដាប់ធ្នាប់សង្គម មន្ត្រីរាជការស្ថិតក្រោមឱវាទទាំងអស់នៃរដ្ឋបាលខេត្តបានខិតខំព្យាយាមដោះស្រាយបានទាន់ពេលវេលា ដោយមិនគិតពីភាពហត់នឿយឡើយ តែងតែគិតគូរនៅកាន់តែគៀកជិតបងប្អូនប្រជាពលរដ្ឋក្នុងនាមជាអភិបាលកិច្ចល្អ។

# ជំពូកទី៣៖ សកម្មភាពការងារជាក់ស្តែង

## ៣.១.ការអនុវត្តការងារ

ក្នុងរយៈពេលកម្មសិក្សាចំនួន ០២ខែ នៅរដ្ឋបាលខេត្តកណ្តាល ខ្ញុំបាទមានឱកាសអនុវត្តន៍ការងារមួយចំនួនជាមួយមន្ត្រីសាលាខេត្តនៅតាមទីចាត់ការ និងការិយាល័យចំណុះថែមទៀតផង ដោយខ្ញុំបាទបានចូលរួមរៀបចំឯកសារ និងរៀបចំសុន្ទរកថាជូនឯកឧត្តមអភិបាលខេត្តក្នុងដំណើរព្រឹត្តិការណ៍ និងកម្មវិធីនានា។ ដោយឡែក លោកនាយកទីចាត់ការអន្តរវិស័យ បានប្រគល់នូវកិច្ចការមួយចំនួនដល់ខ្ញុំបាទបានចូលរួមប្រជុំ និងរៀបចំការសរសេរកំណត់ហេតុកិច្ចប្រជុំមួយចំនួនដូចតទៅ កិច្ចប្រជុំបូកសរុបរបាយការណ៍ប្រចាំខែរបស់គណៈបញ្ជាការឯកភាពខេត្ត, កិច្ចប្រជុំពិនិត្យវឌ្ឍនភាពកែសម្រួលគម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិសាស្ត្រខេត្តកណ្តាល, កិច្ចប្រជុំពិនិត្យ ពិភាក្សា ជាមួយក្រុមការងារគម្រោង JICA ដើម្បីទទួលបានព័ត៌មាន និងទិន្នន័យថ្មីៗ សម្រាប់ការសិក្សាសមិទ្ធិផលគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយលូក្នុងភ្នំពេញ-កណ្តាល, កិច្ចប្រជុំពិភាក្សារកដំណោះស្រាយទប់ស្កាត់ការបាក់ច្រាំងតាមសណ្តរស្ទឹងព្រែកត្នោត ស្ថិតក្នុងសង្កាត់តាខ្មៅ និងសង្កាត់ដើមមៀន ក្រុងតាខ្មៅ, កិច្ចប្រជុំពិនិត្យ ពិភាក្សា លើករណីសុំប្រគល់ការងារបោសសម្អាតកំណាត់ផ្លូវជាតិលេខ២១ ២១អា ២១បេ ជូនលោក អភិបាលក្រុងតាខ្មៅ និងការគ្រប់គ្រងសម្រាមក្នុងក្រុងតាខ្មៅ ជាពិសេសអំពីការដោះស្រាយ សម្របសម្រួល វិវាទដីធ្លីនានាក្នុងភូមិសាស្ត្រខេត្តកណ្តាល។ ចំណែកឯ សប្តាហ៍បន្តបន្ទាប់មកខ្ញុំបាទបានចូលរួមយកវត្តមានក្នុងកិច្ចប្រជុំកម្មវិធីអបអរសាទទិវាប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ ក្រោមប្រធានបទ ដោះស្រាយបញ្ហាគ្រឿងញៀនក្នុងវិបត្តិសុខភាព និងមនុស្សធម៌ខេត្តកណ្តាល ដែលមានសមាជិក សមាជិកា ចូលរួមប្រមាណជាង ៣00នាក់ អញ្ជើញមកពីបណ្តាក្រុង ស្រុក ទាំង១១ មន្ទីរ អង្គភាពជំនាញ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្សនៃសាលាវិទ្យាល័យ ហ៊ុន សែន សេរីភាពក្រុងតាខ្មៅ។

## ៣.២.ការចូលរួមកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ

បន្ទាប់ពីការអនុវត្ត សហការ និងសម្របសម្រួល លើការងារទូទៅក្នុងទីចាត់ការអន្តរវិស័យអស់រយៈពេលប៉ុន្មានថ្ងៃកន្លងមក ខ្ញុំបាទក៏ត្រូវបានអនុញ្ញាតឱ្យចូលរួមកិច្ចប្រជុំ និងកម្មវិធីនានាដូចខាងក្រោម៖

- គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី០៥ ដែលប្រព្រឹត្តិទៅនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំសាលាខេត្ត អគារ A។
- ពិធីសម្ពោធកាត់ខ្សែបូឆ្លងសមិទ្ធផលនានា និងស្រោចស្រពសុគន្ធវារីចៅអធិការវត្តព្រះប្រសប់ នៅវត្តព្រះប្រសប់ ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ដែលប្រព្រឹត្តិទៅនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២២។
- ពិធីជួបជុំមហាគ្រួសាររដ្ឋបាលខេត្តកណ្តាល ដែលប្រព្រឹត្តិទៅនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំសាលាខេត្ត អគារ B។
- ពិធីក្រុងពាលី និងអបអរសាទរពិធីទទួលទេវតាឆ្នាំថ្មី ដែលប្រព្រឹត្តិទៅនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២ នៅមាត់ទន្លេក្រុងតាខ្មៅ។

- កិច្ចប្រជុំ ស្ដីពីការរៀបចំបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភខេត្តកណ្ដាល ដែលប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំសាលាខេត្ត អគារ A។
- ការចុះជួបផ្ទាល់ សួរសុខទុក្ខ ជាមួយបងប្អូនប្រជាពលរដ្ឋរស់នៅសង្កាត់សិត្បូ ក្រុងតាខ្មៅ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២។

## ៣.៣.ការចូលរួមដំណើរទស្សនកិច្ចសិក្សា

នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ជាពេលវេលាដែលជិតបញ្ចប់ការចុះកម្មសិក្សានៅរដ្ឋបាលខេត្តកណ្ដាល ខ្ញុំបាទត្រូវបានអនុញ្ញាតឱ្យចូលរួមដំណើរទស្សនកិច្ចសិក្សាឆ្ពោះទៅកាន់ខេត្តព្រះសីហនុចំនួន ០២ថ្ងៃ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់អង្គភាពជំនាញចំណុះសាលាខេត្ត។ ដំណើរកំសាន្តនេះផងដែរ ក្នុងគោលបំណងដើម្បីស្វែងយល់នូវប្រធានបទចំនួន ០៤ សម្រាប់ធ្វើការចុះសិក្សា ស្រាវជ្រាវ ស្វែងយល់ដូចខាងក្រោម៖

1) ការរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងខេត្តព្រះសីហនុ
2) ការរៀបចំបរិស្ថានអនាម័យអាងប្រព្រឹត្តិកម្មទឹកកង្វក់
3) ការរៀបចំបណ្ដាញអគ្គិសនីក្នុងក្រុងព្រះសីហនុ
4) ការបណ្ដុះបណ្ដាលធនធានមនុស្សរបស់ខេត្តព្រះសីហនុ។

ក្នុងដំណើរនៃការចុះទស្សនកិច្ចឆ្ពោះទៅកាន់ខេត្តព្រះសីហនុនេះ បន្ទាប់ពីបានស្ដាប់នូវបឋកថាដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម គួច ចំរើន អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ ស្ដីពីវឌ្ឍនភាពនៃការរីកចម្រើនរបស់ខេត្តព្រះសីហនុ និងអនុសាសន៍ចែករំលែកបទពិសោធន៍ ចក្ខុវិស័យ ពាក់ព័ន្ធនឹងផ្នែកជាច្រើនទៀតដូចជា ផ្នែកសេដ្ឋកិច្ច ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ផ្នែកឧស្សាហកម្ម ផ្នែកបរិស្ថាន និងផ្នែកអភិវឌ្ឍធនធានមនុស្ស ពិសេសផ្នែកទេសចរណ៍ ដែលខ្ញុំបាទពីមុនមិនដែលបានយល់ជ្រាបច្បាស់។ មិនតែប៉ុណ្ណោះ ដំណើរទស្សនកិច្ចនេះបានរឹតចំណងមិត្តភាព សាមគ្គីភាព និងការប្រាស្រ័យទាក់ទង និងបានបង្ហាញឱ្យឃើញអំពីការយកចិត្តទុកដាក់ ទំនុកបម្រុង របស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់របស់រដ្ឋបាលខេត្ត។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានចុះអង្កេត សិក្សា និងអនុវត្តន៍ផ្ទាល់ទៅលើទីចាត់ការអន្តរវិស័យ នាពេលកន្លងមក ខ្ញុំបាទសង្កេតឃើញថា ទីចាត់ការអន្តរវិស័យនៃរដ្ឋបាលខេត្តកណ្តាល បានអនុវត្តន៍ការងារយ៉ាងរលូនស្របទៅតាមការកំណត់តួនាទីភារកិច្ចក្នុងអនុក្រឹត្យលេខ ២១៦ របស់រាជរដ្ឋាភិបាល ម្យ៉ាងវិញទៀត មន្ត្រីនៅតាមការិយាល័យចំណុះទាំង ០៣ បានបែកចែង និងអនុវត្តន៍តួនាទីភារកិច្ចរបស់ខ្លួនយ៉ាងច្បាស់លាស់ ស្របតាមប្រកាសលេខ ៤២៧៤ របស់ក្រសួងមហាផ្ទៃ ដែលជាកម្លាំងចលករយ៉ាងសំខាន់ក្នុងការជម្រុញ ដំណើរការងារឱ្យទៅមុខកាន់តែរលូន និងមានប្រសិទ្ធភាព ដែលបានជួយដល់ការងារមួយផ្នែកធំរបស់គណៈអភិបាលឱ្យសម្រេចជូនប្រជាពលរដ្ឋបានទាន់ពេលវេលា និងចំគោលដៅឈានទៅដល់ការសម្រេចនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល។

សម្រាប់ខ្ញុំបាទផ្ទាល់ តាមរយៈការចុះកម្មសិក្សានៅរដ្ឋបាលខេត្តកណ្តាលរយៈពេល ០២ខែនេះ ខ្ញុំបាទពិតជាទទួលបាននូវចំណេះដឹងថ្មីកាន់តែច្រើនពីរដ្ឋបាលថ្នាក់ក្រោមជាតិ ពោលគឺរដ្ឋបាលខេត្តកណ្តាល ដោយខ្ញុំបាទបានស្វែងយល់ពីរចនាសម្ព័ន្ធគ្រប់គ្រង និងស្ថានភាពទូទៅរបស់ខេត្តកណ្តាល ក៏ដូចជាការសិក្សា អនុវត្តន៍ជាក់ស្តែងនូវប្រធានបទ "**ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ(របស់រដ្ឋបាលខេត្តកណ្តាល)**" ព្រមទាំងការងាររដ្ឋបាល បែបបទនៃការរៀបចំកិច្ចប្រជុំ ការស្វែងយល់ពីលំហូរឯកសារ និងការរក្សាទុកឯកសារជាដើម ព្រមទាំងបានរៀបចំនូវសុន្ទរកថា និងការសរសេរកំណត់ហេតុជាដើម ដែលជាបទពិសោធន៍ដ៏មានតម្លៃសម្រាប់អភិវឌ្ឍន៍សមត្ថភាពខ្លួននាពេលអនាគត។ បន្ថែមពីលើនេះទៀត ខ្ញុំបាទក៏បង្កើននូវទំនាក់ទំនងជាមួយគណៈអភិបាលខេត្ត មន្ត្រីរាជការ និងបងប្អូនប្រជាពលរដ្ឋ តាមរយៈការចូលរួមកិច្ចប្រជុំ និងវេទិកានានារបស់សាលាខេត្តកណ្តាល ជាពិសេស ការចេះសម្របខ្លួនទៅតាមស្ថានភាពជាក់ស្តែងក្នុងការអនុវត្តន៍ការងារ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ខ្ញុំបាទក៏បានជួបនូវបញ្ហាប្រឈមមួយចំនួនផងដែរ ក្នុងកំឡុងពេលធ្វើកម្មសិក្សានេះដូចជា ភាពគ្មានបទពិសោធន៍នៃការចុះអនុវត្តន៍ការងារជាក់ស្តែង ពោលគឺភាពថ្មីថ្មោងនេះធ្វើឱ្យជួបការលំបាកក្នុងការកំណត់ប្រធានបទជាក់លាក់ និងគោលដៅ ក្នុងការសរសេររបាយការណ៍ ក៏ប៉ុន្តែបញ្ហាប្រឈមនេះត្រូវបានដោះស្រាយតាមរយៈការចង្អុលបង្ហាញពីសំណាក់លោកសាស្ត្រចារ្យណែនាំផ្ទាល់ លោកនាយកទីចាត់ការ និងលោក-លោកស្រីនាយករងទីចាត់ការ លោកប្រធានការិយាល័យ និងលោក-លោកស្រីអនុប្រធានការិយាល័យចំណុះព្រមទាំងមន្ត្រី និងរាមច្បងផងដែរ។

ស្ថិតក្នុងខ្លឹមសារជាសារវន្ត លើប្រធានបទដែលខ្ញុំបានលើកយកមកសិក្សា ស្រាវជ្រាវ ទៅលើស្ថានភាពដែលបានកើតឡើងជាក់ស្តែងទាក់ទងវិវាទដីធ្លីទាំងឡាយ និងការវិភាគលើការដោះស្រាយតាមរយៈករណីសិក្សាដែលអាចធ្វើការឆ្លុះបញ្ចាំងទៅលើចំណុចទាំងអស់នៅក្នុងប្រធានបទ។ ដីធ្លីមានសារៈសំខាន់ណាស់សម្រាប់បងប្អូនប្រជាពលរដ្ឋដែលភាគច្រើនរស់នៅពឹងអាស្រ័យ ដោយតម្រូវការដីបានកើនឡើងជាលំដាប់ ដូច្នេះ វិវាទដីធ្លីនៅតែជាបញ្ហាក្តៅ និងរសើបសម្រាប់ប្រទេសកម្ពុជាដែលមិនអាចជៀសវាងបាន។ ជាការពិតណាស់ មូលហេតុដែលបណ្តាល

ឱ្យមានវិវាទដីធ្លីដោយសារកត្តាមួយចំនួនរួមផ្សំដូចជា កត្តានយោបាយ កត្តាសេដ្ឋកិច្ច កត្តាភូមិសាស្ត្រ កត្តាសង្គម និងកង្វះចំណេះដឹងផ្នែកច្បាប់ដីធ្លីជាដើម ដែលធ្វើឱ្យវិវាទដីធ្លីបន្តកើនឡើង និងក្លាយជាបញ្ហាស្មុគស្មាញពីមួយថ្ងៃទៅមួយថ្ងៃ។ វិវាទនៅតែបន្តកើតឡើង និងដោះស្រាយមិនចេះចប់មិនចេះហើយ ដោយសារបញ្ហាដីធ្លីជាប្រភពចម្បងនៃអ្វីៗទាំងអស់រួមទាំងអំណាច និងទ្រព្យសម្បត្តិ ចំណែកការអនុវត្តច្បាប់នៅមានកម្រិតអ្នកមានប្រាក់ ឬឈ្មួញឆក់ឱកាសកេងចំណេញពីស្ថានការណ៍ដោយបន្លំយកដីរដ្ឋធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។ ទន្ទឹមនេះ កង្វះខាតលិខិតបទដ្ឋានគតិយុត្ត មួយចំនួននៅមានភាពមិនច្បាស់លាស់ និងស៊ីចង្វាក់គ្នានៅឡើយ ដូច្នេះ តម្រូវមានការធ្វើវិសោធនកម្មលើច្បាប់មួយចំនួន និងកែសម្រួល ឬលុបចោលនូវលិខិតបទដ្ឋានគតិយុត្ត ដើម្បីបន្សុំច្បាប់ទាំងនោះឱ្យសមស្របទៅតាមឋានានុក្រម។

សរុបសេចក្ដីមក យើងអាចធ្វើការសន្និដ្ឋានបានថា រាជរដ្ឋាភិបាលបានខិតខំកសាងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ដើម្បីដោះស្រាយបញ្ហាដីធ្លីដែលកើតមានឡើង ប៉ុន្តែនៅមានភាពកង្វះខាតការអនុវត្តច្បាប់ដែលវាមិនអាចនាំឱ្យគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រេចបានជោគជ័យទាំងស្រុងនោះឡើយ ទោះបីជាមានចំណុចខ្វះចន្លោះ និងនៅសេសសល់មួយចំនួនលើការអនុវត្តជាក់ស្ដែង ត្រូវទាមទារឱ្យមានការពង្រឹង និងបំពេញបន្ថែមលើចំណុចខ្វះខាតនានា ដែលសព្វថ្ងៃរាជរដ្ឋាភិបាលក៏កំពុងតែបានគិតគូរ ដើម្បីដោះស្រាយវិវាទទាំងនេះតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលបានគ្រោងទុក។

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សា អង្កេត ស្រាវជ្រាវ ស្វែងយល់ និងចងក្រងនូវប្រធានបទរបស់ខ្ញុំបាទស្តីអំពី "**ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ**(**របស់រដ្ឋបាលខេត្តកណ្តាល**)"រួចចប់សព្វគ្រប់មកសង្កេតឃើញថា រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែបន្តធានា ពង្រឹង ការអនុវត្តច្បាប់ដែលមានស្រាប់ដោយប្រកាន់យកភាពយុត្តិធម៌ តម្លាភាព សុចរិត ស្មោះត្រង់ មិនប្រកាន់និន្នាការនយោបាយ ពិសេសមានគណនេយ្យភាពជាមួយបងប្អូនប្រជាពលរដ្ឋដែលស្នើសុំអន្តរាគមន៍ជួយដោះស្រាយ សម្របសម្រួលដូចខាងក្រោម៖

- អំពីការធ្វើកំណែទម្រង់ដីធ្លី ឬផ្តល់ដីសម្បទានសេដ្ឋកិច្ចជូនក្រុមហ៊ុនឯកជនក្នុងការអភិវឌ្ឍអ្វីមួយ តែងតែមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋក្នុងតំបន់កំពុងអភិវឌ្ឍនោះ រាជរដ្ឋាភិបាលកម្ពុជាគួរតែសិក្សាកំណត់តម្លៃដោះស្រាយសំណងជាប្រាក់គោលនយោបាយឱ្យបានសមរម្យ និងមិនស្ថិតក្រោមរូបភាពគំរាមគំហែង។
- គួរសិក្សាលើគម្រោងដីសម្បទានសេដ្ឋកិច្ចទាំងឡាយណាដែលពិនិត្យឃើញថា ត្រូវបានរងផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ បរិស្ថាន និងធនធានមានជីវិត។ល។
- គួរជូនដំណឹង ផ្សព្វផ្សាយ ជាសាធារណៈឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅតំបន់ ឬទីតាំងភូមិសាស្ត្រដែលរាជរដ្ឋាភិបាលបានកំណត់ទុកជាសម្បត្តិសាធារណៈរដ្ឋ។
- ធានាយន្តការនៃការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ឱ្យមានភាពយុត្តិធម៌ឯករាជ្យ អព្យាក្រឹត្យមិនលំអៀងដល់គូភាគី។
- មិនធ្វើទុក្ខបុកម្នេញលើសកម្មជនដីធ្លីរូបណាដែលបានតស៊ូមតិ ដែលត្រូវជាប់ទោសដោយសារតែសេរីភាពនៃការបញ្ចេញមតិទាមទារស្វែងរកយុត្តិធម៌ចំពោះការរំលោភសិទ្ធិរបស់ពួកគេ។
- ផ្តន្ទាទោសដល់បុគ្គល ឬជនទាំងឡាយណា ដែលបានចូលរំលោភកាន់កាប់ដីកម្មសិទ្ធិឯកជន ឬសាធារណៈរបស់រដ្ឋ លុបបំបាត់វប្បធម៌កេងប្រវ័ញ្ច និងត្រូវបណ្តេញចេញដោយបង្ខំ ឬចាត់វិធានការរដ្ឋបាលឱ្យបានតឹងរឹង។
- ពន្លឿនដំណើរការនីតិវិធីចុះបញ្ជីបណ្ណកម្មសិទ្ធិជាប្រព័ន្ធឱ្យមានសភាពឆាប់រហ័សជាងនេះ សម្រាប់បម្រើសេវាធារណៈជូនប្រជាពលរដ្ឋទូទៅ។
- អំពីការស៊ើបអង្កេតត្រូវមានគណៈកម្មការចំពោះកិច្ចដែលមិនមានភាពលំអៀង ម៉ត់ចត់ ច្បាស់លាស់ និងឯករាជភាពលើករណីវិវាទទាំងឡាយ និងដោះស្រាយជាអទិភាពលើវិវាទណាដែលប្រជាពលរដ្ឋបានស្នើសុំ។
- អាជ្ញាធរមូលដ្ឋានរាល់ពេលចុះហត្ថលេខាលើលិខិតទិញ-លក់ ផ្ទេរសិទ្ធិ អំណោយផ្តាច់ ត្រូវពិនិត្យឱ្យបានច្បាស់លាស់នូវឯកសារ និងទីតាំងដីផ្ទាល់ ជៀសវាងពេលចុះហត្ថលេខារួចធ្វើឱ្យមានភាពមិនប្រក្រតីលើលិខិតដែលបង្កឱ្យមានវិវាទកើតឡើង។

# ឯកសារយោង

## I. គេហទំព័រ

- គេហទំព័រhttps://km.wikipedia.org/wiki/ខេត្តកណ្ដាល
- គេហទំព័រដើមរបស់រដ្ឋបាលខេត្តកណ្ដាល(https://www.kandal.gov.kh).

## II. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- អនុក្រឹត្យ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ស្រុក របស់រាជរដ្ឋាភិបាល
- ប្រកាសលេខ ៤២៧៤ ស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទីភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះរបស់ក្រសួងមហាផ្ទៃ
- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ភូមិបាលឆ្នាំ២០០១
- គោលនយោបាយដីធ្លី"សៀវភៅសដីធ្លី"
- អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- ប្រកាសលេខ ១១២ ដនស.ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី។

## III. លិខិតរដ្ឋបាល និងឯកសារផ្សេងៗ

- សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២១ ខេត្តកណ្ដាល ចេញផ្សាយខែមករា ឆ្នាំ២០១៩
- របាយការណ៍ស្ដីពី លទ្ធផលការងាររយៈពេល០១ ឆ្នាំ២០២១ របស់ទីចាត់ការអន្តរវិស័យ
- កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី និងនគរូបនីយកម្ម របស់លោកគ្រូ ហាប់ ផល្លី។

## **តារាងឧបសម្ព័ន្ធ**

| | |
|---|---|
| **ឧបសម្ព័ន្ធទី១៖ ឯកសារពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាលខេត្តកណ្ដាល** | |
| ១. | បញ្ជីរាយនាមមន្ត្រីរាជការរចនាម្ព័ន្ធសាលាខេត្តកណ្ដាលឆ្នាំ២០១៩ |
| ២. | ការបែងចែកតួនាទីភារកិច្ចជូននាយក-នាយករងទីចាត់ការ ប្រធាន-អនុប្រធានការិយាល័យ និងមន្ត្រីក្រោមឱវាទរបស់ទីចាត់ការអន្តរវិស័យ |
| ៣. | រចនាសម្ព័ន្ធគ្រប់គ្រងរបស់ទីចាត់ការអន្តរវិស័យ |
| ៤. | ទម្រង់របាយការណ៍ប្រចាំឆ្នាំរបស់ទីចាត់ការអន្តរវិស័យ របាយការណ៍ស្តីពី លទ្ធផលនៃការអនុវត្តការងាររយៈពេល០១ឆ្នាំ (ឆ្នាំ២០២១)។ |
| **ឧបសម្ព័ន្ធទី២៖ ឯកសារពាក់ព័ន្ធនឹងដំណើរការនៃការចុះទស្សនកិច្ចសិក្សា** | |
| ១. | លិខិតលេខ ១២៣៤ សជណ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តកណ្ដាល |
| ២. | លិខិតបញ្ជាបេសកកម្មលេខ ១២៩៤ លបក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តកណ្ដាល |
| ៣. | របាយការណ៍ស្តីពី លទ្ធផលនៃដំណើរទស្សនកិច្ចសិក្សារបស់សិក្ខាកាម ដើម្បីស្វែងយល់អំពីការរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធនានា និងការអភិវឌ្ឍរបស់រដ្ឋបាលខេត្តព្រះសីហនុ។ |
| **ឧបសម្ព័ន្ធទី៣៖ ឯកសារពាក់ព័ន្ធនឹងករណីសិក្សា** | |
| ១. | ពាក្យសុំអន្តរាគមន៍របស់ឈ្មោះ ញៀម ម៉ុល ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ |
| ២. | ចំណារដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម អភិបាលខេត្ត ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ |
| ៣. | លិខិតបញ្ជាបេសកកម្មចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ |
| ៤. | លិខិតអញ្ជើញចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ |
| ៥. | ដីកាសម្រេចរបស់តុលាការកំពូលលេខ ៩៣ ដស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ |
| ៦. | កំណត់ហេតុស្តីពី ការអនុវត្តដីកាសម្រេចរបស់តុលាការកំពូល ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១ |
| ៧. | កំណត់ហេតុស្តីពី ការអនុវត្តដីកាសម្រេចរបស់តុលាការកំពូល ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ |
| ៨. | កំណត់ហេតុសម្របសម្រួលលើករណីសំណើសុំអន្តរាគមន៍របស់ឈ្មោះ ញៀម ម៉ុល ជាមួយឈ្មោះ ស៊ឹម ឡុង និងសំណើសុំអន្តរាគមន៍របស់ឈ្មោះ ញៀម ម៉ុល ស្នើហាមឃាត់ការសាងសង់សំណង់របស់ឈ្មោះ ខេង សុខ ស្ថិតនៅភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំអន្តរាគមន៍

នាងខ្ញុំឈ្មោះ [redacted] ឆ្នាំកំណើត១៩៥៨ មានមុខរបរ ធ្វើចំការ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ១៤៧ ភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ ទូរស័ព្ទលេខ ៖ [redacted]

**សូមគោរពជូន**

**ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!*

**កម្មវត្ថុ ៖** សំណើរសុំអន្តរាគមន៍ ដើម្បីអនុវត្តដីកាសម្រេចលេខ ៩៣ ដស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់តុលាការកំពូល និងស្នើសុំអន្តរាគមន៍ហាមឃាត់ការសាងសង់សំណង់គ្រប់ប្រភេទ នៅលើដីដែលមិនទាន់បានអនុវត្តដីកាសម្រេចនូវឡើយរវាងឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted]។

**យោង ៖** -ដីកាសម្រេចលេខ៩៣ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់តុលាការកំពូល។

-កិច្ចព្រមព្រៀងបញ្ចប់ទំនាស់ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥។

-កំណត់ហេតុស្តីពីការអនុវត្តដីកាសម្រេចរបស់តុលាការកំពូលចុះថ្ងៃទី១៦ខែកក្កដាឆ្នាំ២០២០។

-កំណត់ហេតុស្តីពីការអនុវត្តដីកាសម្រេចរបស់តុលាការកំពូលចុះថ្ងៃទី១១ខែតុលាឆ្នាំ២០២១។

-លិខិតរដ្ឋបាលស្រុកកៀនស្វាយសុំផ្អាកការសាងសង់របងព្រុំដីចុះថ្ងៃទី១៨ខែសីហាឆ្នាំ២០២០។

តបតាមកម្មវត្ថុ និងយោងខាងលើនាងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអភិបាលខេត្ត** មេត្តាជ្រាបថា៖ នាងខ្ញុំ និងគូភាគីបានបញ្ចប់ទំនាស់តាមការព្រមព្រៀងដូចបានភ្ជាប់ជូនខាងលើប៉ុន្តែកន្លងមកការអនុវត្តដីកាសម្រេចមិនបានត្រឹមត្រូវឡើយដោយលោក [redacted] បានចុះផ្ទាល់ទីតាំងដីវាស់វែងអោយភាគីឈ្មោះ [redacted] និងឈ្មោះ [redacted] បានធ្វើរបងថ្មបានសម្រេចរហូតមកដល់ពេលនេះស្រាប់តែនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង០៦ល្ងាច ភាគីឈ្មោះ [redacted] និងឈ្មោះ [redacted] និងបក្សពួកបានយកសម្ភារៈសម្រាប់បុកគ្រឹះបន្តចូលទាំងយប់ ហើយនាងបានទៅជម្រាបដល់ លោក [redacted] ប៉ុន្តែគាត់បានឆ្លើយថាចាំគាត់ទៅឃាត់ រហូតដល់ពេលនេះការឃាត់របស់គាត់មិនមានប្រសិទ្ធភាពឡើយដោយមូលហេតុការដោះស្រាយរបស់គាត់មិនមានតម្លាភាព។

**ឯកឧត្តមអភិបាលជាទីគោរព**! ភាគីឈ្មោះ [redacted] បានឃុបឃិតគ្នាជាប្រព័ន្ធលួចធ្វើប្លង់ដីមុនការអនុវត្តដីកាសម្រេច ដែលទង្វើបែបនេះវាផ្ទុយអំពីច្បាប់បានកំណត់។

សូម **ឯកឧត្តមអភិបាល** មេត្តាជួយអន្តរាគមន៍ដូចមានចែងក្នុងកម្មវត្ថុខាងលើ ដោយក្តីអនុគ្រោះបំផុត។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីនាងខ្ញុំ។

ថ្ងៃអង្គារ ០១កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅភូមិទួលក្របៅ,ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

**ស្នាមមេដៃស្តាំ**



[redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកណ្ដាល**

លេខៈ ៥៩១...ល.ប.ប

## លិខិតបញ្ជាបេសកកម្ម

**យោង** ៖ - សំណើរបស់ឈ្មោះ [redacted] ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។

- ចំណារដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម អភិបាលខេត្ត ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២។

**អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល**

| | |
|---|---|
| **ឧទ្ទេសនាម** | ៖ លោក **សាយ ចាន់តារា** មន្ត្រីសាលាខេត្តកណ្ដាល |
| **ធ្វើដំណើរទៅកាន់** | ៖ ស្រុកកៀនស្វាយ។ |
| **ដើម្បី** | ៖ ចុះពិនិត្យ សិក្សា ស្រាវជ្រាវ និងសម្របសម្រួលលើសំណើសុំអន្តរាគមន៍ ដើម្បីអនុវត្តដីកាសម្រេចលេខ ៩៣ ជស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់តុលាការកំពូល និងស្នើសុំអន្តរាគមន៍ហាមឃាត់ការសាងសង់សំណង់លើដីមិនទាន់បានអនុវត្តដីការសម្រេចរវាងឈ្មោះ [redacted], [redacted], [redacted]។ |
| **មធ្យោបាយដំណើរ** | ៖ ផ្ទាល់ខ្លួន។ |
| **ថ្ងៃចេញដំណើរ** | ៖ ថ្ងៃទី០៧..ខែមិថុនា.ឆ្នាំ២០២២ |
| **ថ្ងៃត្រឡប់មកវិញ** | ៖ ថ្ងៃទី.១០...ខែ.មិថុនា.ឆ្នាំ២០២២ |

អាស្រ័យហេតុនេះសូមបណ្ដាអង្គភាពមានសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ មេត្តាជួយសម្រួលក្នុងដំណើរបេសកកម្មនេះឱ្យបានជោគជ័យតាមការគួរ៕

ថ្ងៃ[illegible]...ខែជេស្ឋ..ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

កណ្ដាល ថ្ងៃទី០៧..ខែ.មិថុនា..ឆ្នាំ២០២២

**ជ.អភិបាលខេត្ត**

**នាយករដ្ឋបាល**

គ្រុយ ម៉ាឡែន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកណ្ដាល**
លេខ: ៣០៤ សណន

ការប្រញាប់

ថ្ងៃអង្គារ ៨កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
កណ្ដាល ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០២២

**<u>លិខិតអញ្ជើញ</u>**

**យោង ÷** - លិខិតស្នើសុំអន្តរាគមន៍ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់ឈ្មោះ [redacted]។
- ចំណារដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអភិបាលខេត្ត ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២។

**<u>អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល</u>**

**សូមគោរពអញ្ជើញ** :- លោក **សុក កាន់ណារិទ្ធ** ប្រធានមន្ទីរ ដ.ន.ស.សខេត្ត
- លោក **ពុំ ចាន់នី** ប្រធានការិយាល័យបច្ចេកទេស នៃមន្ទីរ ដ.ន.ស.ស ខេត្ត

**ដើម្បីចូលរួម** : កិច្ចប្រជុំពិនិត្យ សិក្សា ស្រាវជ្រាវ និងសម្របសម្រួលលើសំណើសុំអន្តរាគមន៍ដើម្បីអនុវត្តដីកាសម្រេចលេខ ៩៣ ជស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់តុលាការកំពូល និងស្នើសុំអន្តរាគមន៍ហាមឃាត់ការសាងសង់សំណង់លើដីមិនទាន់បានអនុវត្តដីការសម្រេចរវាងឈ្មោះ [redacted], [redacted], [redacted]។

**ក្រោមកិច្ចសម្របសម្រួល** : **លោក សាយ ចាន់តារា** មន្ត្រីទីចាត់ការអន្តរវិស័យសាលាខេត្ត

**ដែលនឹងប្រព្រឹត្តទៅ** : នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២

**ពេលវេលាម៉ោង** : ៩៖០០នាទី ព្រឹក

**ទីកន្លែងជួបជុំ** : នៅសាលាប្រជុំសាលាស្រុកកៀនស្វាយ

**ត.ប.អភិបាលខេត្ត**
**នាយករដ្ឋបាល**

គ្រួយ ម៉ាឡែន

អាសយដ្ឋាន ផ្លូវជាតិលេខ២ ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល ព្រះរាជាណាចក្រកម្ពុជា | NR #2, Doem Mean Village, Sangkat Doem Mean, Takhmau, Kandal Province, Cambodia.
Tel: 023 42 55 58 • Fax: 023 42 55 55 • Web: www.kandal.gov.kh • Email: admin@kandal.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿងរដ្ឋប្បវេណី
លេខ:០៨
ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣
ដីកាសម្រេច
លេខ: ៩៣ ដស
ចុះថ្ងៃទី..ខែ...ឆ្នាំ២០១៥

# ដីកាសម្រេច

-ដើមចោទឈ្មោះ [redacted] (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ ផ្ទេរសិទ្ធិឱ្យឈ្មោះ[redacted]។

-មានលោកស្រី [redacted] និងកញ្ញា [redacted] ជាមេធាវីតំណាងដោយអាណត្តិ

-ចុងចម្លើយឈ្មោះ [redacted] (ដើមបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

-ចុងចម្លើយឈ្មោះ [redacted] (ដើមបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

<u>កម្មវត្ថុ:</u> ប្តឹងទាមទារដី និងសុំឱ្យរុះរើរបងចេញពីដី

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ០៨ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៣ របស់តុលាការកំពូល។

-បានឃើញបណ្តឹងសាទុក្ខលេខ៣២២ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ របស់ឈ្មោះ[redacted], [redacted] ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២២ក្រVI.ច ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល។

-បានឃើញដីកាសម្រេចលេខ៤០៨ ដស "ថ" ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ របស់តុលាការកំពូល។

-បានឃើញពាក្យសុំដកបណ្តឹងឈប់ប្តឹងផ្តល់ និងបញ្ចប់ទំនាស់ចុះថ្ងៃទី.. ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ឈ្មោះ[redacted] (ដើមចោទ) និងឈ្មោះ[redacted] ជាចុងចម្លើយ។

តុលាការកំពូល

-យល់ឃើញថា: តាមពាក្យសុំដកបណ្តឹង ឈប់ប្តឹងផ្តល់ និងបញ្ចប់ទំនាស់ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ គូភាគីបានព្រមព្រៀងគ្នា បញ្ចប់ទំនាស់ហើយ ដូចមានកិច្ចព្រមព្រៀង បញ្ចប់ទំនាស់ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ២០១៥ ដែលមានការដឹងពីអាជ្ញាធរភូមិ ទួលក្របៅ និងអាជ្ញាធរឃុំ គគី ភ្ជាប់មកជាមួយផង។ដោយគូភាគីមានឆន្ទៈស្រុះស្រួលបញ្ចប់ទំនាស់ហើយ នោះគប្បី តុលាការកំពូល សម្រេច តាមឆន្ទៈរបស់គូភាគី។

ហេតុដូច្នេះ

សម្រេច

១-ទទួលពាក្យសុំដកបណ្តឹង របស់គូភាគីចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ២០១៥។

២-ទទួលស្គាល់ការព្រមព្រៀងរបស់គូភាគី ទៅតាមខ្លឹមសារ នៃកិច្ចព្រមព្រៀងចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៥ ។

-ដីកាសម្រេចនេះធ្វើនៅថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ។

| | | |
|---|---|---|
| ឯកឧត្តម | ទិត ឫទ្ធី | ជាប្រធាន |
| លោក | យស់ សូរឡឿន | ជាចៅក្រម |
| លោក | ឌី ឆេង | ជាចៅក្រម |
| លោក | ស៊ិន បញ្ញាឧត្ត | ជាចៅក្រម |
| លោក | អ៊ុច គីមស្រ៊ី | ជាចៅក្រម |
| លោក | ហេង ច្រឹយ៉ា | ជាចៅក្រម |
| លោក | សោម សិរីវឌ្ឍ | ជាចៅក្រម |
| លោក | សេង នាង | ជាចៅក្រម |
| លោក | គង់ សារាឌាត | ជាចៅក្រម |
| លោក | សុខ ម៉ៅ | ជាក្រឡាបញ្ជី |

---

បានឃើញ

ភ្នំពេញ ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០១៥

ប្រធាន

ទិត ឫទ្ធី

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ- ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥

ក្រឡាបញ្ជី

សុខ ម៉ៅ

ភាគីដើមចោទ | ភាគីចុងចម្លើយ

[redacted] | [redacted]

បានឃើញ និងបញ្ជាក់ថា
គូភាគីពិតជាបានព្រមព្រៀងស្រុះស្រួលគ្នា
និងបញ្ចប់ទំនាស់ហើយបានផ្តិតមេដៃ
នៅចំពោះមុខអាជ្ញាធរ ភូមិ មែន ។
ថ្ងៃទី......២១......ខែ..តុលា....ឆ្នាំ ២០១៥
**មេភូមិ** [signature]

[signature]
ខាំ_ឆ្នា

[illegible]
បានឃើញ និងបញ្ជាក់ថា
គូភាគីពិតជាបានព្រមព្រៀងស្រុះស្រួលគ្នា
និងបញ្ចប់ទំនាស់ហើយបានផ្តិតមេដៃ
នៅចំពោះមុខអាជ្ញាធរ ឃុំ មែន ។
ថ្ងៃទី......៣០......ខែ..តុលា....ឆ្នាំ ២០១៥
មេឃុំ [signature]

គង់_ចេង


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ : 020787349
[redacted]
ស្រុកកៀនស្វាយ ខេត្តកណ្ដាល
ស្រុកកៀនស្វាយ ខេត្តកណ្ដាល
កំពស់
១៦០ ស.ម
ហត្ថលេខា
មេដៃស្ដាំ
មានសុពលភាពដល់ថ្ងៃទី ២៣.០២.២០១៩
កណ្ដាល ថ្ងៃទី ២៣.០២.២០០៩
ក្នុងករណីបាត់ ឬ ខូចត្រូវរាយការណ៍ជូនភ្នាក់ងារមានសមត្ថកិច្ច



នាមត្រកូលនិងនាម: [redacted] 010062167 (01)

ថ្ងៃខែឆ្នាំកំណើត: ១៨.០៤.១៩៥៧ ភេទ: ប្រុស កំពស់: ១៦៣ ស.ម

ទីកន្លែងកំណើត: ឃុំគគីរ ស្រុកកៀនស្វាយ កណ្ដាល

អាសយដ្ឋាន: ផ្ទះ១៨៥អឺ០ ផ្លូវ៦៣ ភូមិ២

សង្កាត់បឹងកេងកងទី ១ ខណ្ឌចំការមន ភ្នំពេញ

សុពលភាព: ២០.០៦.២០១៤ ដល់ថ្ងៃ ១៩.០៦.២០២៤

ភិនភាគ: ប្រជ្រុយចំ. ១,៥ស.ម [illegible]

IDKHM0100621675<<<<<<<<<<<<<<<

5704185M2406190KHM<<<<<<<<<<<6

SIM<<LORNG<<<<<<<<<<<<<<<<<<<<

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

Nation – Religion – King

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

Khmer Identity Card

ក្នុងករណីបាត់ ខូច ឬផុតសុពលភាព ត្រូវរាយការណ៍ជូនសមត្ថកិច្ច

អ្នកប្រើអត្តសញ្ញាណប័ណ្ណខុសច្បាប់ត្រូវផ្តន្ទាទោសតាមច្បាប់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

## កំណត់ហេតុស្តីពីការអនុវត្តដីកាសម្រេចរបស់តុលាការកំពូល

ឆ្នាំពីរពាន់ម្ភៃមួយ ខែតុលា ថ្ងៃទីដប់មួយ វេលាម៉ោងប្រាំបួនព្រឹក នៅស្របតាមបណ្តោយផងផ្លូវជាតិលេខ១ ក្នុងភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល អាជ្ញាសាលា នៃសាលាដំបូងខេត្តកណ្តាល និងដោយមានការចូលរួមសហការអនុវត្តពីក្រុមការងារសាលាស្រុកផងនោះ បានចុះអនុវត្តដីកាសម្រេចលេខ ៩៣ ងស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់តុលាការកំពូល ដោយផ្អែកតាមសំណុំរឿងអនុវត្តដោយបង្ខំលេខ ០៣៧ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ និងសំណុំរឿង លេខ ០៩០ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល ដែលមានសមាសភាពចូលរួមអនុវត្តដូចជា៖

| ល.រ | ឈ្មោះ | តួនាទី | ហត្ថលេខា |
|---|---|---|---|
| ០១ | លោក ពៅ គីមលី | អភិបាលរងស្រុកកៀនស្វាយ | |
| ០២ | លោក ឈន សុផាន់ | អនុការិ- ជ ន ស ភ | |
| ០៣ | លោក ស៊ូ សុខនារ៉េត | មន្ត្រីភូមិបាល | |
| ០៤ | លោក សៀង វណ្ណឆៃ | មេបញ្ជាការរងអាវុធហត្ថស្រុក | |
| ០៥ | លោក មាស បញ្ញា | នាយប៉ុស្តិ៍គគីរ | |
| ០៦ | លោក ស៊ុំ សារឿន | ក្រុមប្រឹក្សា ឃុំគគីរ | |

មុនពេលពេលចុះដល់ទីតាំងដែលត្រូវធ្វើការអនុវត្តស្ថិតនៅភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល រួចមក យើងបានជួបជុំពិភាក្សាដើម្បីរកដំណោះស្រាយឲ្យគ្រប់ភាគីទទួលយកបានទាំងអស់គ្នា ជៀសវាងខូចប្រយោជន៍ដល់គូភាគី ។ បន្ទាប់មកអាជ្ញាសាលាបានអានខ្លឹមសារនៃដីកាសម្រេចលេខ ៩៣ ងស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់តុលាការកំពូល ដែលទទួលស្គាល់ការព្រមព្រៀងរបស់គូភាគី ទៅតាមខ្លឹមសារ នៃកិច្ចព្រមព្រៀង ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៥ ដែលបានឯកភាពគ្នាប្រគល់នឹងទទួលយក សិទ្ធិកាន់កាប់លើផ្ទៃដីមួយកន្លែងដែលមានទីតាំងស្ថិតនៅស្របតាមបណ្តោយផ្លូវជាតិលេខ១ ក្នុងភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ខាងត្បូងទល់នឹងផ្លូវជាតិលេខ១ ខាងកើតទល់នឹងឈ្មោះ [redacted] ខាងលិចទល់នឹងឈ្មោះ [redacted] ខាងមុខគម្លាតចេញពីជញ្ជាំងផ្ទះចំនួន ៤ម៉ែត្រ៣តឹកចំណែកចំហៀងផ្ទះខាងក្រោយ គម្លាតចេញពីជញ្ជាំងផ្ទះ៤ម៉ែត្រ ដោយឡែក ខាងក្រោយផ្ទះយកស្មើនឹងព្រំរបងដីរបស់ឈ្មោះ [redacted] ។ ក្រោយពីបាន

...ះអាងរបស់ឈ្មោះ [redacted] ក៏ដូចជាការលើកឡើងរបស់មេធាវីតំណាង ពួកខ្លួនយោង...
...ព្រមព្រៀង ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ និងដីកាសម្រេចលេខ ៩៣ ដស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់តុលាការកំពូល ចំណែកភាគីខាងលោកស្រី [redacted] មិនឯកភាពឱ្យវាស់វែង ត្រង់ចំណុច (ដោយឡែក ខាងក្រោយផ្ទះយកស្មើនឹងព្រំរបងដីរបស់ឈ្មោះ [redacted]) នៃកិច្ចព្រមព្រៀង ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ រវាងឈ្មោះ [redacted] និងឈ្មោះ [redacted] ឡើយ ។

តាមមតិរបស់លោកអភិបាលរងស្រុក សុំលើកពេលអនុវត្ត ដើម្បីទុកលទ្ធភាពឱ្យរដ្ឋបាលស្រុក ធ្វើការស្រាវជ្រាវលើចំណុច មិនឯកភាពគ្នានេះ ។ ដូចនេះ ដើម្បីឱ្យមានភាពច្បាស់លាស់សម្រាប់គ្រប់ភាគីទទួលយកបាន អាជ្ញាសាលាសម្រេចលើកពេលអនុវត្តទៅពេលក្រោយទៀត ។

ភាគីខាងលោកស្រី [redacted] សំណូមពរឱ្យ ភូមិបាលស្រុក បើក ក្រូគី ចំនួនពីរនាក់ មានឈ្មោះ [redacted] ឈ្មោះ [redacted] ដើម្បីប្រគល់ដីទំនាស់ជាមួយឈ្មោះ [redacted] ។

ភាគីខាងឈ្មោះ [redacted] សំណូមពរពេលអនុវត្តលើកក្រោយ សូមឱ្យទៅទីតាំងអនុវត្តផ្ទាល់តែម្តងទោះបីមិនមានការឯកភាព ពីភាគីម្ខាងទៀតក៏ដោយ ។

ការអនុវត្តត្រូវបានបញ្ចប់នៅវេលាម៉ោងដប់មួយព្រឹក នាថ្ងៃខែឆ្នាំដដែល ហើយបានអានកំណត់ហេតុឱ្យភាគី និងអ្នកចូលរួមស្តាប់ ហើយទទួលស្គាល់ថាត្រឹមត្រូវ រួចយល់ព្រមចុះហត្ថលេខា និងផ្តិតមេដៃទុកជាភស្តុតាង ។

ភាគីនៃការអនុវត្ត

សមាសភាពចូលរួម

អាជ្ញាសាលា

[redacted]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

## កំណត់ហេតុស្តីពីការអនុវត្តដីកាសម្រេចរបស់តុលាការកំពូល

ឆ្នាំពីរពាន់ម្ភៃ ខែកក្កដា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងប្រាំបួនព្រឹក នៅស្របតាមបណ្តោយដងផ្លូវជាតិលេខ១ ក្នុងភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល អាជ្ញាសាលា នៃសាលាដំបូងខេត្តកណ្តាល បានចុះអនុវត្តដីកាសម្រេចលេខ ៩៣ ដស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់តុលាការកំពូល ដោយផ្អែកតាមសំណុំរឿងអនុវត្តដោយបង្ខំលេខ ០៣៧ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល ដែលមានសមាសភាពចូលរួមអនុវត្តដូចជា៖

| ល.រ | ឈ្មោះ | តួនាទី | ហត្ថលេខា |
|---|---|---|---|
| ០១ | លោក ពៅ គីមលី | អភិបាលរងស្រុកកៀនស្វាយ | |
| ០២ | លោក ឃឿន សុន | មន្ត្រីភូមិបាល | |
| ០៣ | លោក វ៉ុន សារ៉ាន់ | មេបញ្ជាការរងអាវុធហត្ថស្រុក | |
| ០៤ | លោក សេង សាវុន | នាយរងប៉ុស្តិ៍ | |
| ០៥ | លោក ហៃ វន | នាយរងប៉ុស្តិ៍ | |
| ០៦ | លោកស្រី ថោង សំអឿន | ជំទប់ទី២ ឃុំគគីរ | |
| ០៧ | លោកស្រី ខាំ ឡា | មេភូមិទួលក្របៅ | |

នៅពេលចុះដល់ទីតាំងនៃការអនុវត្តស្ថិតនៅភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល រួចមកឃើញថា នៅលើទីតាំងដែលត្រូវអនុវត្តនេះ គឺពុំមានមនុស្សស្នាក់នៅទេ។ បន្ទាប់មកអាជ្ញាសាលាបានអានខ្លឹមសារនៃដីកាសម្រេចលេខ ៩៣ ដស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់តុលាការកំពូល ដែលទទួលស្គាល់ការព្រមព្រៀងរបស់គូភាគី ទៅតាមខ្លឹមសារ នៃកិច្ចព្រមព្រៀង ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៥ ដែលបានឯកភាពគ្នាប្រគល់នឹងទទួលយកសិទ្ធិកាន់កាប់លើផ្ទៃដីមួយកន្លែងដែលមានទីតាំងស្ថិតនៅស្របតាមបណ្តោយផ្លូវជាតិលេខ១ ក្នុងភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ខាងត្បូងទល់នឹងផ្លូវជាតិលេខ១ ខាងកើតទល់នឹងឈ្មោះ [redacted] ខាងលិចទល់នឹងឈ្មោះ [redacted] ខាងមុខគម្លាតចេញពីជញ្ជាំងផ្ទះចំនួន ៤ម៉ែត្រ៣តឹកចំណែកចំហៀងផ្ទះខាងក្រោយ គម្លាតចេញពីជញ្ជាំផ្ទះ៤ម៉ែត្រ ដោយឡែក ខាងក្រោយផ្ទះយកស្មើនឹងព្រំរបងដីរបស់ឈ្មោះ [redacted]។ ក្រោយមកសមាសភាពសម្រុះបានធ្វើការវាស់វែងតែដីចំណីផ្លូវដែលមានប្រវែង៣០ ម៉ែត្រ

ពីអ័ក្សផ្លូវជាតិលេខ១ ចំណែកឯដីមានប្រវែងសល់ពីដីចំណីផ្លូវនេះ យើងមិនអាចធ្វើការវាស់វែងបានទេ ដោយសារតតិយជនឈ្មោះ [redacted] ដែលមានព្រំដីជាប់នឹងដីរបស់ឈ្មោះ [redacted] ពុំឯកភាពក្នុងការវាស់វែងនេះទេ ដោយមូលហេតុប៉ះពាល់នឹងដីរបស់គាត់ ដោយផ្អែកតាមបណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $G_5$ 0496 ឆ្នាំ១៩៩២ របស់គណៈកម្មាធិការប្រជាជនស្រុកកៀនស្វាយ ខេត្តកណ្ដាល។ ចំណែកឯភាគីឈ្មោះ [redacted] បានផ្អែកតាមគំនូសបង្ហាញរូបរាងដី ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩២ របស់ឈ្មោះ [redacted] ដែលតម្កល់ទុកនៅការិយាល័យភូមិបាលស្រុកកៀនស្វាយ ដែលដីរបស់ឈ្មោះ [redacted] មានព្រំខាងត្បូងទល់ជាមួយឈ្មោះ [redacted] ។

តាមមតិរបស់លោកអភិបាលរងស្រុក ដោយពិនិត្យឃើញថា ដីរបស់លោកស្រី [redacted] ជាប់ពាក់ព័ន្ធជាមួយដីរបស់ [redacted] ។ ដូចនេះក្នុងនាមរដ្ឋបាលស្រុក សុំពេលឱ្យមន្ត្រីជំនាញសុរិយោដីស្រុក ធ្វើវាស់វែងដីរបស់ភាគីទាំងពីរភាគីទៅតាមប្លង់ដែលកំពុងកាន់កាប់បច្ចុប្បន្ន ។ ដូចនេះ ដើម្បីឱ្យមានភាពច្បាស់លាស់សម្រាប់គ្រប់ភាគីទទួលយកបាន អាជ្ញាសាលាសម្រេចលើកពេលអនុវត្តទៅពេលក្រោយទៀត ។

ការអនុវត្តត្រូវបានបញ្ចប់នៅវេលាម៉ោងមួយព្រឹក នាថ្ងៃខែឆ្នាំដដែល ហើយបានអានកំណត់ហេតុឱ្យភាគី និងអ្នកចូលរួមស្តាប់ ហើយទទួលស្គាល់ថាត្រឹមត្រូវ រួចយល់ព្រមចុះហត្ថលេខា និងផ្តិតមេដៃទុកជាភស្តុតាង។

| អាជ្ញាសាលា | ភាគីនៃការអនុវត្ត | អ្នកធ្វើកំណត់ហេតុ |
| --- | --- | --- |



[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកណ្ដាល
រដ្ឋបាលស្រុកកៀនស្វាយ
លេខ ០៣២ សជណ

**អភិបាល នៃគណៈអភិបាលស្រុកកៀនស្វាយ**

**<u>ជម្រាបមក</u>**

លោក [redacted] លោក [redacted] និងលោកស្រី [redacted] រស់នៅភូមិខ្ទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

**<u>កម្មវត្ថុ</u>** ៖ សុំផ្អាកការសាងសង់របងព្រុំដី

**<u>យោង</u>** ៖ - សំណើរសុំអនុវត្តដីកាសម្រេចលេខ៩៣ជស ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៥ ។

- សេចក្ដីសម្រេចលេខ ១១៩រប/២០របស់តុលាការកំពូលចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ។
- កំណត់ហេតុចុះអនុវត្តដីការបស់តុលាខេត្តកណ្ដាល ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២០ ។

តាមកម្មវត្ថុ និងយោងខាងលើនេះ ខ្ញុំសូមភាគីពាក់ព័ន្ធទាំងបីផ្អាកការសាងសង់របងបណ្ដោះអាសន្នមួយរយៈរង់ចាំ ការចុះវាស់វែងតាមប្លង់ដែលមាន និងការសម្រេចពីតុលាការជាមុនសិន ។

សូមបងប្អូនទាំងបីភាគី ទទួលនូវការគោរពរាប់អានពីខ្ញុំ ។

ថ្ងៃសុក្រ ១០រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កៀនស្វាយ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២០
អភិបាលស្រុក

អ៊ុំ ឈាង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកណ្តាល**

## <u>កំណត់ហេតុ</u>

**កិច្ចប្រជុំសម្របសម្រួលលើករណីសំណើសុំអន្តរាគមន៍របស់ឈ្មោះ [redacted] ជាមួយឈ្មោះ [redacted] និងសំណើសុំអន្តរាគមន៍របស់ឈ្មោះ [redacted] ស្នើហាមឃាត់ការសាងសង់សំណង់របស់ឈ្មោះ [redacted] ស្ថិតនៅភូមិទួលក្របៅ ស្រុកកៀនស្វាយ ខេត្តកណ្តាល**

ឆ្នាំពីរពាន់ម្ភៃពីរ ខែមិថុនា ថ្ងៃទីប្រាំបី វេលាម៉ោងប្រាំបួន នាទីព្រឹក នៅសាលប្រជុំសាលាស្រុកកៀនស្វាយ មានកិច្ចប្រជុំមួយក្រោមការសម្របសម្រួលរបស់**លោក សាយ ចាន់តារា មន្ត្រីទីចាត់ការអន្តរវិស័យ និងលោក អ៊ូ ឈាង អភិបាល នៃគណៈអភិបាលស្រុកកៀនស្វាយ** ដើម្បីសម្របសម្រួល លើករណីសំណើសុំអន្តរាគមន៍របស់ឈ្មោះ [redacted] ជាមួយឈ្មោះ [redacted] និងសំណើសុំអន្តរាគមន៍របស់ឈ្មោះ [redacted] ស្នើហាមឃាត់ការសាងសង់សំណង់របស់ [redacted] មានទីតាំងស្ថិតនៅភូមិទួលក្របៅ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

***(សមាសភាពចូលរួមប្រជុំដូចមានក្នុងបញ្ជីវត្តមានភ្ជាប់ជាមួយ)***

ជាកិច្ចចាប់ផ្តើម**លោក សាយ ចាន់តារា មន្ត្រីទីចាត់ការអន្តរវិស័យ** បានមានមតិសំណេះសំណាលបើកអង្គប្រជុំ និងថ្លែងអំណរគុណដល់សមាជិក សមាជិកា នៅក្នុងអង្គប្រជុំទាំងមូល និងបានលើកឡើងថា កិច្ចប្រជុំនាពេលនេះ គឺជាយន្តការសម្របស្រួមលដល់គូភាគីដើម្បីឱ្យការអនុវត្តសាលដីការប្រព្រឹត្តទៅដោយរលូន អាចទទួលយកបានគ្រប់ភាគី។ ចំពោះករណីនេះ គឺតុលាការកំពូលបានសម្រេចរួចរាល់ហើយ តាមរយៈដីការសម្រេចលេខ ៩៣ ជស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ដោយយោងតាមពាក្យបណ្តឹង របស់គូភាគីចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៥។ អង្គប្រជុំ សូមស្នើភាគីដែលពាក់ព័ន្ធ អនុវត្តតាមកិច្ចព្រមព្រៀងចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៥ ដែលបានព្រមព្រៀងបញ្ចប់ទំនាស់រួចរាល់ហើយ។

កិច្ចបន្ទាប់**លោក អ៊ូ ឈាង អភិបាលស្រុកកៀនស្វាយ៖** បានមានប្រសាសន៍ថា ករណីនេះ តុលាការកំពូលបានសម្រេចរួចរាល់ហើយ ដោយឡែកសាលាដំបូងខេត្តកណ្តាល ក៏បានចុះអនុវត្តដីកាសម្រេចរបស់តុលាការកំពូល ចំនួន ០២លើកហើយ ប៉ុន្តែដោយសារតែមានការជំទាស់តវ៉ាពីភាគី ទើបមិនទាន់អនុវត្តបានសម្រេច។ ចំពោះដីរបស់ឈ្មោះ [redacted] ដែលមានទំនាស់ជាមួយឈ្មោះ [redacted] នោះគឺ ឈ្មោះ [redacted] បានធ្វើកិច្ចសន្យាបញ្ចប់វិវាទរួចរាល់ហើយ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ដោយទទួលសំណងជាទឹកប្រាក់ ចំនួន ៦០,០០០ ដុល្លារសហរដ្ឋអាមេរិក។ ក្រោយបានបញ្ចប់ទំនាស់ទើប ការិយាល័យភូមិបាលស្រុកកៀនស្វាយ ចុះវាស់វែងកំណត់និយាមកាព្រំប្រទល់ ជូនឈ្មោះ [redacted] និងបានចេញប័ណ្ណកម្មសិទ្ធិរួចរាល់ដោយមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល លេខ ក.ណ.០២៤១២៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ ដោយឡែកភាគីឈ្មោះ [redacted] មិនទាន់ឯកភាព យល់ស្របចំណុចផ្នែកខាងកន្ទុយព្រំដីទើបបានដាក់ពាក្យស្នើសុំមកកាន់អាជ្ញាធរជួយដោះស្រាយនិងសម្របសម្រួល។

មតិ**លោក** [redacted]៖ ករណីនេះ ខ្ញុំបាទបានដោះស្រាយបញ្ចប់រួមមកហើយ ដោយដោះស្រាយជាប្រាក់គោលនយោបាយថ្នូរនឹងការទាមទារ ក្នុងនោះមានកំណត់ហេតុបញ្ចប់អំពីការប្រគល់-ទទួលប្រាក់ត្រឹមត្រូវ

ដូចនេះដីមានវិវាទខាងលើមិនជាប់ពាក់ព័ន្ធជាមួយគ្រួសាររបស់ខ្ញុំបាទនោះឡើយ ប៉ុន្តែមកដល់បច្ចុប្បន្ននេះភាគីឈ្មោះ [redacted] បានដាក់ពាក្យបណ្ដឹង និងទប់ស្កាត់ការសាងសង់សំណង់លើដីបន្ថែមទៀត សូមស្នើសុំអាជ្ញាធរស្រុកមេត្តាជួយរកយុត្តិធម៌ដល់ខ្ញុំផង។

**មតិលោកស្រី** [redacted]៖ ចំពោះដីចំណីផ្លូវជាតិជារបស់ខ្ញុំបានកាន់កាប់រហូតមកក្នុងប្រវែងប្រមាណ ២៥ម៉ែត្រ បន្ទាប់មកឈ្មោះ [redacted] បានឱ្យខ្ញុំចាក់ដីលុបអូរនោះ ចាំបន្តធ្វើការវាស់វែងដីជាក្រោយបន្ថែមទៀត។ សូមអាជ្ញាធរមេត្តាដោះស្រាយនៅចំណុចកន្ទុយដីដែលខ្ញុំមិនទាន់ឯកភាពជាប់ជាមួយព្រំប្រទល់ឈ្មោះ [redacted] ជូនគ្រួសាររបស់ខ្ញុំផង។

**មតិលោកស្រី** [redacted] (**កូនឈ្មោះ** [redacted])៖ ស្នើភាគីឈ្មោះ [redacted] យកសាលដីការរបស់តុលាការ និងឯកសារគតិយុត្តពាក់ព័ន្ធយកមកធ្វើការជជែកគ្នាក្នុងអង្គប្រជុំទាំងមូល ព្រោះករណីនេះតុលាការបានសម្រេចចេញសាលដីការរួចរាល់ដើម្បីបញ្ចប់ទំនាស់ខាងលើ ហេតុអ្វីភាគីឈ្មោះ [redacted] នៅតែបន្តប្តឹងជំទាស់គ្រួសារ និងហាមឃាត់ការសាងសង់សំណង់លើដីកម្មសិទ្ធិរបស់ខ្ញុំទៀត។ សូមស្នើសុំអាជ្ញាធរមេត្តាបន្តឱ្យនាងខ្ញុំបានបន្តបុកគ្រឹះសាងសង់សំណង់នៅលើដីកម្មសិទ្ធិរបស់ខ្ញុំជាបន្តទៀត។

**<u>មតិសរុបរបស់ប្រធានអង្គប្រជុំ៖</u>**

ករណីនេះជាសមត្ថកិច្ចរបស់តុលាការ ដូចនេះរដ្ឋបាលខេត្ត ស្រុក នឹងចូលរួមសហការអនុវត្តតែប៉ុណ្ណោះ ប៉ុន្តែស្នើសុំគូភាគីទំនាស់ត្រូវតែ អនុវត្តតាមការសម្រេចរបស់តុលាការកំពូល តាមរយៈដីកាសម្រេចលេខ ៩៣ ជស ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ និងត្រូវអនុវត្តតាមកិច្ចព្រមព្រៀងចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៥ ដែលបានព្រមព្រៀងគ្នាបញ្ចប់ទំនាស់រួចរាល់ហើយ។

- ប្រគល់ជូនភារកិច្ចជូនមន្ទីរដ.ន.ស.សខេត្ត រួមជាមួយភូមិបាលស្រុកសហការចុះពិនិត្យ វាស់វែងកំណត់ទីតាំងដីខាងលើឱ្យបានជាក់លាក់ និងច្បាស់លាស់។

  បន្ទាប់ពីបានប្រជុំ ពិនិត្យ ពិភាក្សា វាស់វែងជាក់ស្តែងក្រុមការងារបានចុះពិនិត្យលើទីតាំងដីផ្ទាល់មានដូចតទៅ៖

  - ដីរបស់ឈ្មោះ [redacted] និងប្រពន្ធ [redacted] មានស្ថានភាពដីបាន ចុះបញ្ជីនៅឆ្នាំ២០១៨បានត្រឹមត្រូវតាមប្លង់គ្រូគី(ប្លង់ដាច់ដោយជុំឆ្នាំ២០១៨) ហើយមិនមានជាន់ជាមួយនឹងដីរបស់ឈ្មោះ [redacted] ឡើយ។
  - ភាគីឈ្មោះ [redacted] បានកាន់កាប់ អាស្រ័យផល លើទីតាំងដីជាក់ស្តែង ដែលផ្ទេរមរតកពីឪពុកម្តាយឈ្មោះ [redacted] ដោយមានធ្វើរបងព័ទ្ធជុំវិញដី និងបានធ្វើប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ(ប្លង់ដាច់ដោយជុំឆ្នាំ២០១៨) ដោយសារតែបានធ្វើកិច្ចសន្យាបញ្ចប់វិវាទ ជាមួយឈ្មោះ [redacted] រួចរាល់ហើយ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ដោយផ្តល់នូវសំណងជាទឹកប្រាក់ ចំនួន **៦០,០០០ ដុល្លារសហរដ្ឋអាមេរិក។**
  - ភាគី [redacted] មិនមានឯកសារគតិយុត្តណាមួយមកសំអាងហេតុ រីឯប្រវត្តិកាន់កាប់ដីជាក់ស្តែងនោះក៏មិនត្រឹមត្រូវតាមការទាមទារដែរ(មិនស្គាល់ព្រំដីច្បាស់លាស់)។

- ភាគីឈ្មោះ [redacted] នៅតែមិនទាន់ឯកភាពទទួលយកចំណុចកន្ទុយព្រំដី ទោះបីជាតុលាការកំពូលបានចេញសាលដីការសម្រេចជាធរមាន។
- ឈ្មោះ [redacted] ដែលបានប្តឹងជំទាស់នោះ ត្រូវយកឯកសារពាក់ព័ន្ធលើការកាន់កាប់ ដីសព្វថ្ងៃដែលមានការពាក់ព័ន្ធទាំងអស់ រួមទាំងការកាន់កាប់ដីចំណីផ្លូវដែលទាមទារចង់បានប្រគល់ជូនក្រុមការងារដើម្បីពិនិត្យ ពិភាក្សា បន្តទៀត។

ទំ.2 / 2

- ប្រសិនបើភាគីមិនមានគោលជំហរឯកភាពបញ្ចប់ទំនាស់នោះ រដ្ឋបាលខេត្ត ស្រុក សូមបង្វែរករណីវិវាទខាងលើជូនភាគីដោះស្រាយតាមប្រព័ន្ធតុលាបន្តទៀត។
- អង្គប្រជុំសម្រេចលើកកិច្ចប្រជុំ ក្រុមការងារបន្តសហការជាមួយរដ្ឋបាលខេត្ត ស្រុក កោះអញ្ជើញភាគីពាក់ព័ន្ធមកប្រជុំម្តងទៀតនាឱកាសក្រោយ។

កិច្ចប្រជុំ បានបញ្ចប់នៅវេលាម៉ោងដប់មួយ និងសាមសិបនាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងការទទួលខុសត្រូវខ្ពស់។

**បានឃើញ និងឯកភាព** **អ្នកកត់ត្រា**

**ប្រធានអង្គប្រជុំ**